Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

54411

# សៀវភៅមគ្គុទេសក៍ស្តីអំពីនីតិវិធីអធិការកិច្ច លើសហគ្រាសចំណីអាហារ និងភេសជ្ជៈ នៅកម្ពុជា






សេវាប្រឹក្សាយោបល់លើបរិយាកាសវិនិយោគ | ក្រុមធនាគារពិភពលោក

IFC International Finance Corporation World Bank Group
MIGA World Bank Group Multilateral Investment Guarantee Agency
THE WORLD BANK
EUROPEAN UNION

សហប្រតិបត្តិការជាមួយ ហ្វាំងឡង់ អៀកឡង់ ហូឡង់ ណូវែលសេឡង់ និងស្វីស

# សៀវភៅមគ្គុទេសក៍ស្ដីអំពីនីតិវិធីអធិការកិច្ច លើសហគ្រាសចំណីអាហារ និងឱសថៈ នៅកម្ពុជា







សេវាប្រឹក្សាយោបល់លើបរិយាកាសវិនិយោគ | ក្រុមធនាគារពិភពលោក

IFC International Finance Corporation World Bank Group

MIGA World Bank Group Multilateral Investment Guarantee Agency

THE WORLD BANK

EUROPEAN UNION

សហប្រតិបត្តិការជាមួយ ហ្វាំងឡង់ អៀកឡង់ ហូឡង់ ណូវែលសេឡង់ និងស្វីស


មេសា ២០១០

## អំពីសេវាប្រឹក្សាយោបល់លើបរិយាកាសវិនិយោគនៃក្រុមធនាគារពិភពលោក

សេវាប្រឹក្សាយោបល់លើបរិយាកាសវិនិយោគនៃក្រុមធនាគារពិភពលោក ជួយរដ្ឋាភិបាលក្នុងការអនុវត្តនីដំណើរការ កែទម្រង់ សំដៅកែលំអបរិយាកាសអាជីវកម្ម ជំរុញ និងរក្សាការវិនិយោគដែលនាំអោយមាន ទីផ្សារដែលមានលក្ខណៈ ប្រកួតប្រជែង កំណើនសេដ្ឋកិច្ច និងការបង្កើតការងារ ។ ថវិការសំរាប់ការងារនេះ ផ្តល់ឱ្យដោយក្រុមធនាគារពិភពលោក ( សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ភ្នាក់ងារធានាវិនិយោគទុនពហុភាគី និងធនាគារពិភពលោក ) និងដៃគូម្ចាស់ជំនួយច្រើន ជាងដប់ប្រាំផ្សេងទៀតដែលធ្វើការងារដោយផ្អែកលើមូលដ្ឋាន នៃសេវាប្រឹក្សាយោបល់សំរាប់វិនិយោគទុនបរទេស (multi-donor FIAS platform) ។

ការបកស្រាយ ការរកឃើញ និងការសន្និដ្ឋានដែលមាននៅក្នុងសៀវភៅនេះ គឺជាគំនិតរបស់អ្នកនិពន្ធ និងមិនប្រាកដថា ឆ្លុះបញ្ចាំងពីទស្សនះរបស់នាយកប្រតិបត្តិនៃក្រុមធានាគារពិភពលោក ឬរដ្ឋាភិបាលដែលគេតំណាងអោយនោះទេ ។

# មាតិកា

*បញ្ជីតារាង* ...... *iii*
*បញ្ជីរូបភាព* ...... *iv*
*ពាក្យកាត់* ...... *v*
*សេចក្តីថ្លែងអំណរគុណ* ...... *vi*

**សេចក្តីផ្តើម** ...... ១
**អធិការកិច្ចលើសុវត្ថិភាពចំណីអាហារ** ...... ៤
១. សហគ្រាសកែច្នៃចំណីអាហារបឋម ...... ៤
២. សហគ្រាសកែច្នៃចំណីអាហារបន្ទាប់ ...... ៩
២.១ អធិការកិច្ចរោងចក្រ និងសិប្បកម្ម ...... ៩
២.២ ការចុះបញ្ជី លិខិតបញ្ជាក់សញ្ញាស្តង់ដារ និងការបិទស្លាកសញ្ញាផលិតផលចំណីអាហារដែលវេចខ្ចប់រួច ...... ១២
**អធិការកិច្ចលើការគ្រប់គ្រងបរិស្ថាន** ...... ២១
**អធិការកិច្ចការងារ** ...... ២៨
**ឧបសម្ព័ន្ធ** ...... ៣៧
**ឧបសម្ព័ន្ធ ១ A:** ចំណាត់ថ្នាក់សត្តឃាតដ្ឋាន ...... ៣៨
**ឧបសម្ព័ន្ធ ១ B:** បែបបទសុំលិខិតអនុញ្ញាតបង្កើតសត្តឃាតដ្ឋាន ...... ៣៩
**ឧបសម្ព័ន្ធ ១ C:** បែបបទសុំលិខិតអនុញ្ញាតអាជីវកម្មពិឃាតសត្វ ...... ៤៣
**ឧបសម្ព័ន្ធ ១ D:** លិខិតអនុញ្ញាតបង្កើតសត្តឃាតដ្ឋាន ...... ៤៦
**ឧបសម្ព័ន្ធ ១ E:** លិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ ...... ៤៧
**ឧបសម្ព័ន្ធ ១ F:** ប្រកាសស្តីពីទីតាំង និង បទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់សត្តឃាតដ្ឋាន ...... ៤៨
**ឧបសម្ព័ន្ធ ១ G:** ប្រកាសស្តីពីបទបញ្ជាផ្ទៃក្នុងរបស់សត្តឃាតដ្ឋាន ...... ៥៤
**ឧបសម្ព័ន្ធ ១ H:** បញ្ជីរាយឈ្មោះជំងឺសំខាន់ៗ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសាច់ និង ផលិតផលសត្វ ...... ៥៨

**ឧបសម្ព័ន្ធ ២ A:** សហគ្រាសសិប្បកម្មតម្រូវសុំប្រកាសអនុញ្ញាត................................................ ៦០

**ឧបសម្ព័ន្ធ ២ B:** ពាក្យស្នើសុំវិញ្ញាបនបត្រ និងអាជ្ញាបណ្ណ័ប្រើសញ្ញាបញ្ជាក់ផលិតផល......................៦១

**ឧបសម្ព័ន្ធ ២ C:** កិច្ចព្រមព្រៀងអាជ្ញាបណ្ណ័សំរាប់ការប្រើប្រាស់វិញ្ញាបនប័ត្រ និងសញ្ញាស្តង់ដារ ........ ៦៦

**ឧបសម្ព័ន្ធ ២ D:** វិញ្ញាបនប័ត្រផលិតផលសំរាប់ការអនុលោមតាមការចុះបញ្ជីផលិតផលឧស្សហកម្ម និងស្តង់ដារកម្ពុជា **CS 001:2000**............................................................... ៧១

**ឧបសម្ព័ន្ធ ២ E:** អជ្ញាប័ណ្ណសំរាប់ប្រើសញ្ញាបញ្ជាក់ផលិតផល CS 001:2000 ............................. ៧២

**ឧបសម្ព័ន្ធ ២ F:** អជ្ញាប័ណ្ណសំរាប់ប្រើសញ្ញាបញ្ជាក់ផលិតផល...................................................៧៣

**ឧបសម្ព័ន្ធ ៣ A:** ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយមានការសុំអនុញ្ញាតិពីក្រសួងបរិស្ថាន មុននឹងបញ្ចេញចោលនូវសំណល់រាវរបស់ខ្លួន ឬដឹកទៅទីដទៃ..............................៧៤

**ឧបសម្ព័ន្ធ ៣ B:** កំរិតកំណត់ស្តង់ដារសំលេងអតិបរមា ដែលអនុញ្ញាតនៅតំបន់ សាធារណៈ និង តំបន់លំនៅដ្ឋាន (dB(A)) ..........................................................................៧៥

**ឧបសម្ព័ន្ធ ៣ C:** កំរិតកំណត់ស្តង់ដារសំរាប់ត្រួតពិនិត្យសំលេងក្នុងទីតាំង រោងជាង រោងចក្រឧស្សាហកម្ម.................................................................................៧៥

**ឧបសម្ព័ន្ធ ៣ D:** ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់...........................................................៧៥

**ឧបសម្ព័ន្ធ ៣ E:** តារាងត្រួតពិនិត្យ អធិការកិច្ចបរិស្ថាន............................................................៧៦

**ឧបសម្ព័ន្ធ ៣ F:** ថ្លៃវិភាគប៉ារ៉ាម៉ែត្រគីមីមួយចំនួន...................................................................៧៩

**ឧបសម្ព័ន្ធ ៣ G:** ការពិន័យចំពោះការមិនគោរពបទបញ្ញត្តិនៃច្បាប់ពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ .....................................................៨២

**ឧបសម្ព័ន្ធ ៤ A:** សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស.......................................................... ៨៥

**ឧបសម្ព័ន្ធ ៤ B:** សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន..........................................................................៨៦

**ឧបសម្ព័ន្ធ ៤ C:** សៀវភៅបើកប្រាក់......................................................................................... ៨៩

**ឧបសម្ព័ន្ធ ៤ D:** សេចក្តីប្រកាសជូនដំណឹងស្តីពីបុគ្គលិក............................................................៩១

# បញ្ជីតារាង

**តារាង ១:** អនុក្រឹត្យ ប្រកាស និងលក្ខខណ្ឌតម្រូវទាក់ទងនឹងការត្រួតពិនិត្យសត្តឃាតដ្ឋាន.............៤

**តារាង ២:** ការណែនាំសំរាប់ប្រតិបត្តិករសត្តឃាត ................................................................ ៨

**តារាង ៣:** ច្បាប់ និង លក្ខខណ្ឌតម្រូវទាក់ទងនឹងអធិការកិច្ចរោងចក្រ និងសិប្បកម្មកែច្នៃចំណីអាហារបន្ទាប់..........................................................................................១០

**តារាង ៤:** ការណែនាំសម្រាប់អធិការកិច្ចលើសុវត្ថិភាពចំណីអាហារ និងភេសជ្ជៈ. ..................... ១២

**តារាង ៥:** ច្បាប់ ប្រកាស និងលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការចុះបញ្ជីវិញ្ញាបនប័ត្រផលិតផល និងការបិទស្លាកសញ្ញាផលិតផល.................................................................... ១៣

**តារាង ៦:** ការណែនាំដើម្បីទទួលបានអាជ្ញាប័ណ្ណប្រើសញ្ញាស្តង់ដារកម្ពុជា............................... ១៧

**តារាង ៧:** ការណែនាំដើម្បីទទួលបានអាជ្ញាប័ណ្ណប្រើសញ្ញាចុះបញ្ជីផលិតផល ............................២០

**តារាង ៨:** ច្បាប់ និងអនុក្រឹត្យដែលពាក់ព័ន្ធនឹងអធិការកិច្ចគ្រប់គ្រងបរិស្ថាន............................ ២២

**តារាង ៩:** ការណែនាំសំរាប់អធិការកិច្ចលើការគ្រប់គ្រង់បរិស្ថាន.......................................... ២៧

**តារាង ១០:** ច្បាប់ និងអនុក្រឹត្យដែលពាក់ពន្ធ័នឹងអធិការកិច្ចវិស័យការងារ ................................២៨

**តារាង ១១:** ការណែនាំសំរាប់អធិការកិច្ចការងារ ............................................................... ៣៦

# បញ្ជីរូប


**រូបទី ១:** នីតិវិធីនៃអធិការកិច្ចលើសត្តឃាត ....... ៧

**រូបទី ២:** នីតិវិធីនៃការធ្វើអធិការកិច្ចរោងចក្រ និងសិប្បកម្ម ....... ១១

**រូបទី ៣:** នីតិវិធីនៃការធ្វើអធិការកិច្ចដើម្បីទទួលបានអាជ្ញាប័ណ្ណសម្រាប់ការប្រើសញ្ញាស្តង់ដារកម្ពុជា.. ១៦

**រូបទី ៤:** នីតិវិធីអធិការកិច្ចដើម្បីទទួលបានអាជ្ញាប័ណ្ណសំរាប់ប្រើសញ្ញាចុះបញ្ជីផលិតផល ....... ១៩

**រូបទី ៥:** នីតិវិធីអធិការកិច្ចលើការគ្រប់គ្រងបរិស្ថាន ....... ២៦

**រូបទី ៦:** នីតិវិធីអធិការកិច្ចការងារ ....... ៣៥

# ពាក្យគន្លឹះ

**EIA:** ការវាយតម្លៃផលប៉ះពាល់បរិស្ថាន

**G-PSF:** វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន

**ISC:** វិទ្យាស្ថានស្តង់ដាកម្ពុជា

**Lab:** មន្ទីរពិសោធន៍

**MIME:** ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**MLVT:** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**MoC:** ក្រសួងពាណិជ្ជកម្ម

**MoE:** ក្រសួងបរិស្ថាន

**MoSALVY:** ក្រសួងសង្គមកិច្ច និងយុវនីតិសម្បទា

**MSME:** ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**MSME WG:** ក្រុមការងារ កម្មន្តសាល និងសហគ្រាសធុនតូច និងមធ្យម

**SMEs:** សហគ្រាសធុនតូច និងមធ្យម

**Vet:** មន្ត្រីបសុព្យាបាល

# សេចក្ដីថ្លែងអំណរគុណ

ការធ្វើអធិការកិច្ចគឺជាឧបសគ្គសំរាប់ សហគ្រាសឬ សិប្បកម្មផលិតភេសជ្ជៈ និងចំណីអាហារ ធុនតូច និងមធ្យមនៅកម្ពុជា។ តំណាងផ្នែកឯកជននៃក្រុមការងារ កម្មន្តសាល និងសហគ្រាសធុនតូច និងមធ្យម នៃវេទិការដ្ឋាភិបាល-ផ្នែកឯកជន បានលើកឡើងនូវបញ្ហាថា សហគ្រាសឬ សិប្បកម្មផលិតភេសជ្ជៈ និងចំណីអាហារ មិនបានយល់ដឹងនីតិវិធីនៃការធ្វើអធិការកិច្ច និងនីតិវិធីទាំងនេះមិនមានតម្លាភាព។ ដោយសារពួកគេមិនបានដឹងពីនីតិវិធីទាំងនោះ ពួកគេមានការលំបាកក្នុងការគោរពតាមលក្ខខណ្ឌតំរូវនានា នៃអធិការកិច្ច ហើយធ្វើឱ្យថ្លៃចំណាយក្នុងការគោរពតាមនីតិវិធីទាំងនេះកើនឡើងខ្ពស់។

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ បានរៀបចំ សៀវភៅមគ្គុទេសក៏ស្ដីអំពីនីតិវិធីអធិការកិច្ចលើសហគ្រាសចំណីអាហារ និងភេសជ្ជៈនៅកម្ពុជា ដើម្បីជួយសហគ្រាសទាំនោះក្នុងការគោរពតាមនីតិវិធីអធិការកិច្ច។ សៀវភៅមគ្គុទេសក៏ បង្ហាញពីជំហានលំអិត លកខណ្ឌតំរូវ និងការណែនាំដ៏មានប្រយោជន៏សំរាប់សហគ្រាស ដើម្បីឱ្យពួកគេអាចគោរពតាមនីតិវិធីទាំងនោះបានល្អ។ សៀវភៅនេះក៏បង្ហាញពីនីតិវិធី ក្នុងទំរង់ងាយយល់ ដោយផ្ដល់នូវព័តិមានសំខាន់ៗ និងប្រើប្រាស់ការបង្ហាញតាមបែបគំនូសបំព្រួញ។ ប្រសិនបើសហគ្រាស យល់ដឹងច្រើនជាងមុន និងអាចគោរពតាមនីតិវិធីទាំងនោះយ៉ាងមានប្រសិទ្ធភាព នោះវានឹងសំរាលទំងន់នៃការលំបាកដែលបណ្ដាលមកពីការធ្វើអធិការកិច្ច។ មូលនិធិសំរាប់ការងារនេះត្រូវបានផ្ដល់ឱ្យដោយ សហគមអឺរុប និងមូលនិធិពហុជំនួយទ្រទ្រង់កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គ (**Multi-donor MPDF Trust Fund**) ដែលមូលនិធិទាំងពីរនេះគាំទ្រដល់ការអភិវឌ្ឍន៏សហគ្រាសធុន តូច និងមធ្យមនៅកម្ពុជា។

សៀវភៅមគ្គុទេសក៏នេះមិនអាចកើតឡើងបានទេ ប្រសិនបើគ្មានការគាំទ្រ និងការចូលរួមយ៉ាងសកម្ម ពីមន្ត្រីរបស់ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកសិកម្ម រុកាប្រមាញ់ និងនេសាទ ក្រសួងពាណិជ្ជកម្ម ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រសួងបរិស្ថាន។

ការងារនេះត្រូវបានធ្វើឡើង ក្រោមការដឹកនាំរបស់លោក **Charles Schneider** ។ លោក **សឹម វីរយៈ** ធ្វើសេចក្ដីព្រាងសៀវភៅមគ្គុទេសក៏នេះ។ លោក **ទុ ឃី** ផ្ដល់មតិយោបល់ និងសំរបសំរួលការរៀបរៀងសៀវភៅនេះ។ លោក **ហោ សុនាថ** លោកស្រី **លីលី ស៊ីសម្បត្តិ**

និងតំណាងផ្នែកឯកជននៃក្រុមការងារ កម្មន្តសាល និងសហគ្រាសធុនតូច និងមធ្យម បានផ្ដល់មតិយោបល់ក្នុងកំឡុងពេលធ្វើការស្រាវជ្រាវ និងពង្រាងសៀវភៅនេះ។ លោកស្រី **Ka Ying Yang** និង **Ann Bishop** ជួយកែសំរួលអត្ថបទ ក្នុងសៀវភៅនេះ។ លោកស្រី **គា គន្ធា** ផ្ដល់ការគាំទ្រក្នុងការរចនា ជាទំរង់សៀវភៅមគ្គុទេសក៏នេះឡើង។ លោកស្រី **តាន់ តូនី** បានជួយជ្រមជ្រែងផ្នែករដ្ឋបាល។

# សេចក្តីផ្តើម

សៀវភៅមគ្គុទេសក៍នេះត្រូវបានរៀបចំឡើងតាមសំណើរបស់សមាជិកក្រុមការងារ កម្មន្តសាល និង សហគ្រាសធុនតូច និងមធ្យម នៃវេទិការាជរដ្ឋាភិបាលផ្នែកឯកជន ដើម្បីឆ្លើយតបទៅនឹងបញ្ហារបស់សហគ្រាស កែច្នៃម្ហូបអាហារ និងភេសជ្ជៈ ពាក់ពន្ធ័នឹងការខ្វះព័ត៌មានពីនីតិវិធីនៃការធ្វើអធិការកិច្ច ។ សមាជិកក្រុមការងារកម្មន្តសាល និងសហគ្រាសធុនតូច និងមធ្យម មានតំរូវការលើព័ត៌មានអំពីនីតិវិធីនៃការធ្វើអធិការកិច្ចដើម្បីលើកកំពស់ តម្លាភាព និង កាត់បន្ថយនូវករណីរំលោភបំពាននៃការអនុវត្តនីតិវិធីទាំងនោះ ។

## ទិសាលភាព និងគោលបំណងនៃសៀវភៅមគ្គុទេសក៍

- សៀវភៅមគ្គុទេសក៍នេះរៀបរាប់ អំពីអនុវិស័យសហគ្រាសផលិតភេសជ្ជៈ និងកែច្នៃចំណីអាហារ និងផ្តោតទៅលើនីតិវិធីអធិការកិច្ច លើសុវត្ថិភាពចំណីអាហារ បរិស្ថាន និងការងារ ។
- គោលបំណងនៃសៀវភៅមគ្គុទេសក៍នេះគឺផ្តល់ឱ្យសហគ្រិនផលិតភេសជ្ជៈនិងកែច្នៃចំណីអាហារនូវព័ត៌មានអំពី :
  - ច្បាប់ និងបទបញ្ញត្តិពាក់ពន្ធ័នឹងអធិការកិច្ចលើសហគ្រាសផលិតភេសជ្ជៈ និងកែច្នៃចំណីអាហារ
  - លក្ខខណ្ឌដែលសហគ្រាសត្រូវបំពេញ និង
  - នីតិវិធីអធិការកិច្ចដែលធ្វើឡើងដោយស្ថាប័នអធិការកិច្ចផ្សេងៗ

## តើសៀវភៅមគ្គុទេសក៍នេះមានរចនាសម្ព័ន្ធយ៉ាងដូចម្តេច ?

សៀវភៅមគ្គុទេសក៍នេះ ត្រូវបានរៀបចំឡើងដោយបែងចែកជាបីផ្នែក ។ ផ្នែកទីមួយនិយាយអំពីអធិការកិច្ចទាក់ទងនឹងសុវត្ថិភាពចំណីអាហារ ដែលត្រូវបានបែងចែកបន្តទៀតជា អធិការកិច្ចលើការកែច្នៃចំណីអាហារបឋម (Primary food processing) និងអធិការកិច្ចលើការកែច្នៃចំណីអាហារបន្ទាប់ (Secondary food processing) ។ ផ្នែកទីពីរ និយាយអំពីអធិការកិច្ចលើការគ្រប់គ្រងបរិស្ថាន និងផ្នែកទីបី និយាយអំពីអធិការកិច្ចការងារ ។

## តើអ្នកខ្លះគួរប្រើសៀវភៅមគ្គុទេសក៍នេះ ?

សៀវភៅមគ្គុទេសក៍នេះ គឺសម្រាប់សហគ្រិនផលិតចំណីអាហារនិងភេសជ្ជៈ ដែលកំពុងមានដំណើរការនៅក្នុងប្រទេសកម្ពុជា ប្រើដើម្បី :

- យល់ដឹងឱ្យកាន់តែប្រសើរអំពីនីតិវិធីអធិការកិច្ច
- សន្សំសំចៃពេលវេលាក្នុងការអនុវត្តតាមលក្ខខណ្ឌតំរូវនានា

ស្ថាប័នត្រួតពិនិត្យចំណីអាហារក៏អាចប្រើសៀវភៅមគ្គុទេសក៍នេះជាប្រយោជន៍ក្នុងការផ្តល់ព័តិមានទៅឱ្យសហគ្រិនថ្មីៗផងដែរ ។

## តើសៀវភៅមគ្គុទេសក៍នេះត្រូវបានរៀបរៀងឡើងយ៉ាងដូចម្តេច?

ដំណាក់កាលក្នុងការរៀបចំសៀវភៅណែនាំនេះរួមមានៈ

- ពិនិត្យមើលនូវច្បាប់ និងបទបញ្ញត្តិដែលបង្កើតឱ្យមាននូវលក្ខខណ្ឌតំរូវសំរាប់ការធ្វើអធិការកិច្ចដោយក្រសួងពាក់ពន្ធ័នានា
- ពិគ្រោះយោបល់ពីនីតិវិធីនៃការធ្វើអធិការកិច្ច ជាមួយតំណាងក្រសួងពាក់ពន្ធ័ និងផ្នែកឯកជន និង
- ដាក់បញ្ចូលទៅក្នុងសៀវភៅមគ្គុទេសក៍នេះនូវសំណើ និងយោបល់ផ្សេងៗ

## តើអ្នកខ្លះពាក់ព័ន្ធនឹងអធិការកិច្ចសហគ្រាសផលិតភេសជ្ជៈ និងកែច្នៃចំណីអាហារ?

តួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នអធិការកិច្ចនីមួយៗ ត្រូវបានបង្ហាញនៅក្នុងច្បាប់ អនុក្រិត្យ ប្រកាស និងសារាចរផ្សេងៗ។ ផ្អែកទៅលើច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ការបែងចែកភារកិច្ចនៅក្នុងអនុវិស័យសហគ្រាសផលិត ភេសជ្ជៈ និងកែច្នៃចំណីអាហារ មានដូចតទៅ :

### អធិការកិច្ចលើសុវត្ថិភាពចំណីអាហារ និងភេសជ្ជៈ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវចាប់ពីផលិតកម្មបឋម រហូតដល់ការកែច្នៃចំណីអាហារបឋម។ ចំណែក ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទទួលខុសត្រូវចំពោះ ភេសជ្ជៈ និងការកែច្នៃចំណីអាហារបន្ទាប់។ ប្រសិនបើក្រសួងពាណិជ្ជកម្ម (MoC) អគ្គនាយកដ្ឋានកាំកុងត្រូល (CAMCONTROL) បានរកឃើញថាផលិតផលនៅលើទីផ្សារមានផ្ទុកជាតិគីមី គ្រោះថ្នាក់ ឬមិនគោរពតាមច្បាប់ និងបទបញ្ញត្តិដែលពាក់ព័ន្ធនោះ អគ្គនាយកដ្ឋានកាំកុងត្រូល ដោយមានកិច្ចសហការ

ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចយកសំណាកពីសហគ្រាសរបស់លោកអ្នក ទៅធ្វើការវិភាគក្នុងមន្ទីរពិសោធន៍។

### *តើការកែច្នៃចំណីអាហារបឋមមានន័យយ៉ាងដូចម្តេច ?*

បណ្តាសកម្មភាពទាំងឡាយណាដែលរួមមាន ការលាងសម្អាត ការស្រិត ការចិតសំបក កាត់ និងចិតចំណិត បែននិង អុំ សម្លាប់សត្វ វះពោះ ពន្លះស្បែក យកឆ្អឹងចេញ ច្រៀក រក្សាទុកតាមបែបប្រពៃណីដូចជាប្រឡាក់ហាល ឆ្អើរ។ ការបែងចែកនិងចាត់ថ្នាក់ ក្លាស្សេ និងបង្កក ព្រមទាំងការវេចខ្ចប់ផលិតផល ដែលបានឆ្លងកាត់ដំណើរការបែបទាំងនេះ ប៉ុន្តែការកែច្នៃដំបូងមិនរាប់បញ្ចូលនូវសកម្មភាព ដែលត្រូវបានធ្វើឡើងនៅឯទីផ្សារលក់ដុំ និងរាយ ឬទៅលើចំណីអាហារនាំចូលទេ។ សហគ្រាសដែលស្ថិតនៅក្នុងការកែច្នៃចំណីអាហារបឋមរួមមាន សហគ្រាសកែច្នៃត្រីដោយក្លាស្សេ បង្កក ហាល ប្រឡាក់ ឬធ្វើផ្អក រោងម៉ាស៊ីនកិនស្រូវ សត្តឃាតដ្ឋាន។

### *តើការកែច្នៃចំណីអាហារបន្ទាប់មានន័យយ៉ាងដូចម្តេច ?*

ការកែច្នៃនេះនឹងរាប់បញ្ចូលរាល់សកម្មភាពដទៃទៀតដូចជា កិន បន្សុទ សំលាប់មេរោគ (sterilizing) លាយ/កិនបញ្ចូល/ ផ្សំរូបមន្ត ចម្អិន។ល។

សហគ្រាសដែលស្ថិតនៅក្នុងការផលិតភេសជ្ជៈនិងកែច្នៃចំណីអាហារបន្ទាប់រួមមានៈ សហគ្រាសផលិតប្រភេទ សរសៃមី-គុយទាវ-នំបញ្ចុក សហគ្រាសកែច្នៃទឹកជ្រលក់ សហគ្រាសផលិតភេសជ្ជៈ និងស្រា និង សហគ្រាសផលិតចំណីអាហារវេចខ្ចប់។

## អធិការកិច្ចលើការគ្រប់គ្រងបរិស្ថាន :

ក្រសួងបរិស្ថាន គឺជាស្ថាប័នតែមួយគត់ដែលរ៉ាប់រងលើអធិការកិច្ចលើការគ្រប់គ្រងបរិស្ថាន។ អធិការកិច្ចលើការគ្រប់គ្រងបរិស្ថាន អាចធ្វើបានក្នុងតំបន់ ទីក្នុងបរិវេណអគារ លើឬក្នុងមធ្យោបាយដឹកជញ្ជូន ឬទីកន្លែងណាមួយ ដើម្បីរកមើលនូវប្រភព ដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពបរិស្ថាន។ មន្ត្រីអធិការកិច្ចអាចយកសំណាក ពិនិត្យមើលកំណត់ត្រា សួរសំណួរ និង តម្រូវឱ្យម្ចាស់ឬអ្នកទទួលខុសត្រូវនៃប្រភពបំពុលផ្តល់នូវព័ត៌មាន និងឯកសារពាក់ពន្ធ័ ដើម្បីធ្វើរបាយការណ៍ និងជាវត្ថុតាង។

## អធិការកិច្ចការងារ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាស្ថាប័នតែមួយគត់ដែលរ៉ាប់រងលើអធិការកិច្ចការងារ។ ការធ្វើអធិការកិច្ចការងារគឺពាក់ពន្ធ័នឹងសុខភាពកម្មករ ស្ថានភាពការងារ និងសុវត្ថិភាពការងារ។

# អធិការកិច្ចលើសុវត្ថិភាពចំណីអាហារ

## ១. សហគ្រាសកែច្នៃចំណីអាហារបឋម

ជាទូទៅ មានអនុវិស័យបីដែលទាក់ទងទៅនឹងការកែច្នៃចំណីអាហារបឋម: ១.កសិកម្ម ២.ជលផល និង ៣.ផលិតកម្មនិងបសុព្យាបាល។ រហូតមកដល់ពេលបច្ចុប្បន្ននេះ មានតែអនុវិស័យផលិតកម្ម និងបសុព្យាបាល ប៉ុណ្ណោះ ដែលមានបទបញ្ញត្តិពាក់ព័ន្ធនឹងអធិការកិច្ចលើសហគ្រាសកែច្នៃចំណីអាហារបឋម។ ប្រសិនបើសហគ្រិន បើកដំណើរការសហគ្រាសដែលស្ថិតនៅក្នុងការកែច្នៃចំណីអាហារបឋម ដូចការរៀបរាប់ខាងលើ ព្រមទាំងធ្វើប្រតិបត្តិការសត្តឃាតដ្ឋាននោះ បទបញ្ញត្តិដែលពាក់ពន្ធ័នឹងសហគ្រាសមានដូចតទៅ :

- អនុក្រិត្យលេខ ១០៨ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន និងការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- ប្រកាសលេខ ២២៤ ស្តីពីទីតាំង និងបទដ្ឋានបច្ចេកទេសសំរាប់ការសាងសង់សត្តឃាតដ្ឋាន និង
- ប្រកាសលេខ ២២៥ ស្តីពីបទបញ្ជាផ្ទៃក្នុងរបស់សត្តឃាតដ្ឋាន

**តារាង ១: អនុក្រិត្យ ប្រកាស និងលក្ខខណ្ឌតម្រូវទាក់ទងនឹងការត្រួតពិនិត្យសត្តឃាតដ្ឋាន**

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| **អនុក្រិត្យលេខ ១០៨** | | |
| 🕮 ការបង្កើតសត្តឃាតដ្ឋាននិងការធ្វើអាជីវកម្មពិឃាតសត្វ ត្រូវមានលិខិតអនុញ្ញាតចេញដោយនាយកដ្ឋានផ្នែកផលិតកម្ម និងបសុព្យាបាលនៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ✍ ដាក់ពាក្យសុំលិខិតអនុញ្ញាត[១] នៅនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ប្រសិនបើសត្តឃាតដ្ឋានស្ថិត ក្នុងប្រភេទ A (សូមមើលឧបសម្ព័ន្ធ ១ A)<br><br>✍ ដាក់ពាក្យសុំលិខិតអនុញ្ញាតពីការិយាល័យផលិតកម្ម និងបសុព្យាបាល ខេត្ត/ក្រុង ប្រសិនបើ សត្តឃាតដ្ឋានរបស់លោកអ្នក ស្ថិតក្នុងប្រភេទ B (សូមមើលឧបសម្ព័ន្ធ ១ A) | 🗎 លិខិតអនុញ្ញាតចេញដោយនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលដោយមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br><br>🗎 លិខិតអនុញ្ញាតចេញដោយមន្ទីរកសិកម្ម ខេត្ត/ក្រុង តាមសំណើរបស់ការិយាល័យផលិតកម្មនិងបសុព្យាបាល |

[១]ពាក្យសុំមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ១B និង ១C និងគំរូអាជ្ញាប័ណ្ណមានភ្ជាប់នៅឧបសម្ព័ន្ធ ១D និង ១E

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
| --- | --- | --- |
| 🕮 ប្រតិបត្តិករសត្តឃាតមានកាតព្វកិច្ចដូចខាងក្រោម : | | |
| ▪ ប្រគល់លិខិតដឹកជញ្ជូនសត្វ វិញ្ញាបនប័ត្រអនាម័យសត្វ និងអត្តសញ្ញាណប័ណ្ណសត្វ ដល់ភ្នាក់ងារបសុពេទ្យ | ✍ ដាក់ពាក្យសុំលិខិតអនុញ្ញាតដឹកជញ្ជូនវិញ្ញាបនប័ត្រ អនាម័យសត្វ នឹងអត្តសញ្ញាណប័ណ្ណសត្វ | 🗎 លិខិតអនុញ្ញាតដឹកជញ្ជូនវិញ្ញាបនប័ត្រអនាម័យសត្វ និងអត្តសញ្ញាណប័ណ្ណសត្វ |
| ▪ រក្សាទុកសត្វនៅសត្តឃាតដ្ឋាន រយៈពេលពី ១២ ទៅ ២៤ ម៉ោង ដើម្បីត្រួតពិនិត្យសុខភាពសត្វមុនពេលពិឃាត | ✍ រក្សាទុកសត្វនៅសត្តឃាតដ្ឋាន រយៈពេលពី ១២ ទៅ ២៤ ម៉ោង ដើម្បីត្រួតពិនិត្យសុខភាពសត្វ | |
| ▪ បង់កម្រៃសេវាកម្មអធិការកិច្ច | ✍ បង់ថ្លៃសេវាកម្មអធិការកិច្ច[២] | 🗎 បង្កាន់ដៃបង់ប្រាក់ |
| ▪ អនុវត្តតាមបែបបទ និងបទបញ្ញាបសុពេទ្យ នៅពេលដឹកជញ្ជូនសាច់ និងផលិតផលសត្វចេញពីសត្តឃាតដ្ឋាន | ✍ អនុវត្តតាមបែបបទ និងបទបញ្ញា បសុពេទ្យនៅពេលដឹកជញ្ជូនសាច់ និងផលិតផលសត្វចេញពីសត្តឃាតដ្ឋាន | |
| **ប្រកាសលេខ ២២៤ ស្តីពីទីតាំង និងបទដ្ឋានបច្ចេកទេសសំរាប់ការសាងសង់សត្តឃាតដ្ឋាន** | | |
| 🕮 សាងសង់សត្តឃាតដ្ឋានដោយគោរពតាមបទដ្ឋានបច្ចេកទេស | ✍ សុំការណែនាំពីភ្នាក់ងារបសុពេទ្យពាក់ពន្ធ័នឹងបទដ្ឋានបច្ចេកទេសដែលត្រូវគោរពតាម | 🗎 ប្រកាសស្តីពីទីតាំង និងបទដ្ឋានបច្ចេកទេសសំរាប់ការសាងសង់សត្តឃាតដ្ឋាន (សូមមើលតារាងឧបសម្ព័ន្ធ ១ F) |
| **ប្រកាសលេខ ២២៥ ស្តីពីបទបញ្ញាផ្ទៃក្នុងរបស់សត្តឃាតដ្ឋាន** | | |
| 🕮 ដើម្បីធានាអនាម័យសត្វ សាច់ និងផលិតផលមានដើមកំណើតពីសត្វ សំដៅរក្សាបានសុវត្ថិភាពចំណីអាហារ និងសុខភាពសាធារណៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រេចកំណត់នូវបទបញ្ញាផ្ទៃក្នុងសម្រាប់ឱ្យ សត្តឃាតដ្ឋានអនុវត្តតាម (សូមមើលតារាងឧបសម្ព័ន្ធ ១ G សម្រាប់ព័ត៌មានលម្អិត) | ✍ អនុវត្តតាមបទបញ្ញាផ្ទៃក្នុងរបស់សត្តឃាតដ្ឋាន (សូមមើលតារាង ឧបសម្ព័ន្ធ ១ G). | 🗎 ប្រកាសស្តីពីបទបញ្ញាផ្ទៃក្នុងរបស់សត្តឃាតដ្ឋាន |

[២] ប្រកាសស្តីអំពីកម្រៃសេវាធ្វើអធិការកិច្ចលើសត្វ និង ផលិតផលមានដើមកំណើតពីសត្វ នៅជាសេចក្តីព្រាងនៅឡើយ ។ ហេតុដូច្នេះហើយ ថ្លៃសេវាអធិការកិច្ច ប្រែប្រួលពីកន្លែងមួយទៅកន្លែងមួយទៀត ។

## អធិការកិច្ចលើសត្តឃាតៈ

- គោលបំណងនៃអធិការកិច្ច គឺធានាការគោរពតាមវិធានបសុព្យាបាល អនាម័យ និង សុវត្ថិភាពសាច់សត្វ ដើម្បីជាប្រយោជន៍ដល់សុខភាពសាធារណៈ និងបរិស្ថាន។
- អធិការកិច្ចត្រូវបានធ្វើឡើងដោយមន្ត្រីអធិការកិច្ចបសុពេទ្យមកពីការិយាល័យផលិតកម្ម និងបសុព្យាបាល ខេត្ត/ក្រុង នៅឯសត្តឃាតដ្ឋាន។
- សត្តឃាតដ្ឋាននីមួយៗ មានមន្ត្រីអធិការកិច្ចបសុពេទ្យខេត្ត/ក្រុងចំនួន ពីរឬបីនាក់ ដែលស្ថិតនៅសត្តឃាតដ្ឋានជាអចិន្ត្រៃយ៍ ដើម្បីត្រួតពិនិត្យសុខភាពសត្វ អនាម័យសត្តឃាតដ្ឋាន និង សុវត្ថិភាពសាច់សត្វ។
- ដើម្បីបង្កើនល្បឿននៃដំណើរការនៃការធ្វើអធិការកិច្ច សហគ្រាសត្រូវតែមានឯកសារពាក់ព័ន្ធដូចដែលបានបង្ហាញនៅក្នុងតារាងទី ១ ត្រៀមរួចជាស្រេច។

**រូបទី ១: នីតិវិធីនៃអធិការកិច្ចលើសត្តឃាត**




សំគាល់: ការធ្វើអធិការកិច្ច ធ្វើឡើងដោយការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត/ក្រុង

## លក្ខខណ្ឌដែលតំរូវឱ្យប្រតិបត្តិករសត្តឃាតដ្ឋានគោរពតាមៈ

- មុនពេលបង្កើតសត្តឃាតដ្ឋាន ប្រតិបត្តិករត្រូវតែសុំលិខិតអនុញ្ញាត ដែលចេញដោយការិយាល័យផលិតកម្ម និងបសុព្យាបាល ។
- សាងសង់សត្តឃាតដ្ឋានតាមបទបញ្ញត្តិបច្ចេកទេស ដូចមានរៀបរាប់នៅក្នុងតារាងឧបសម្ព័ន្ធ ១ F ។
- ថែរក្សាសត្តឃាតដ្ឋានឱ្យបានស្អាត និងមានសណ្តាប់ធ្នាប់ ដូចបានរៀបរាប់នៅក្នុងតារាងឧបសម្ព័ន្ធ ១ G ។

## លក្ខខណ្ឌដែលប្រតិបត្តិករសត្តឃាតត្រូវបំពេញតាមៈ

- មុនពេលធ្វើអាជីវកម្មសត្តឃាត ប្រតិបត្តិករសត្តឃាតត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាត ដែលចេញដោយការិយាល័យផលិតកម្ម និងបសុព្យាបាល ។

### តារាង ២ៈ ការណែនាំសំរាប់ប្រតិបត្តិករសត្តឃាត

| ជំហាន | ការណែនាំ |
|---|---|
| ជំហានទី ១ | ▪ ដើម្បីជៀសវាងការចុះធ្វើអធិការកិច្ចដោយគ្មានការអនុញ្ញាត សូមសួររកអត្តសញ្ញាណប័ណ្ណ និងលិខិតបេសកកម្ម ដែលចេញដោយនាយកដ្ឋាន/ការិយាល័យផលិតកម្ម និងបសុព្យាបាល<br>▪ សហគ្រាសត្រូវបានស្នើឱ្យបង់កម្រៃសេវាកម្មអធិការកិច្ច និងវិញ្ញាបនប័ត្រអនាម័យ |
| ជំហានទី ២ | ▪ ដូចបានពន្យល់នៅរូបភាពទី១ |
| ជំហានទី ៣ | ▪ សួរមន្ត្រីអធិការកិច្ចថាតើសត្វនោះមានអ្វីខុសប្លែក មុនពេលមន្ត្រីអធិការកិច្ចធ្វើសំណាកគំរូរបស់សត្វទៅមន្ទីរពិសោធន៍ |
| ជំហានទី ៤ | ▪ សហគ្រាសត្រូវបង់ថ្លៃការវិភាគក្នុងមន្ទីរពិសោធន៍ |
| ជំហានទី ៥ | ▪ សត្វដែលមានភាពមិនប្រក្រតីត្រូវដាក់ឱ្យដាច់ដោយឡែកពីសត្វដែលមានភាពប្រក្រតី ហើយរង់ចាំលទ្ធផលពីការវិភាគ ក្នុងមន្ទីរពិសោធន៍<br>▪ សួររកលទ្ធផលពីការវិភាគនៅមន្ទីរពិសោធន៍ |
| ជំហានទី ៦ | ▪ ដូចបានពន្យល់នៅរូបភាពទី១ |
| ជំហានទី ៧ | ▪ ដូចបានពន្យល់នៅរូបភាពទី១ |
| ជំហានទី ៨ | ▪ បន្ទាប់ពីពិឃាត សាច់សត្វ និងផលិតផលពីសត្វត្រូវទុកឱ្យបសុពេទ្យដើម្បីត្រួតពិនិត្យ |
| ជំហានទី ៩ | ▪ ដូចបានបង្ហាញនៅរូបភាពទី១ |
| ជំហានទី ១០ | ▪ ពិនិត្យមើលថា តើសាច់សត្វ និងផលិតផលពីសត្វត្រូវបាន និងបោះត្រា និងមានវិញ្ញាបនប័ត្រអនាម័យ |
| ជំហានទី ១១ | ▪ អាស្រ័យទៅតាមសភាពជម្ងឺ មន្ត្រីអធិការកិច្ចបសុពេទ្យអាចស្នើឱ្យសហគ្រាសបំផ្លាញចោលសត្វនោះ ឬធ្វើការកែច្នៃបន្តទៀត |

## ២. សហគ្រាសកែច្នៃចំណីអាហារបន្ទាប់

### ២.១ អធិការកិច្ចរោងចក្រ និងសិប្បកម្ម

- គោលបំណងនៃអធិការកិច្ចរោងចក្រ និងសិប្បកម្ម គឺដើម្បីធានាការអនុលោមតាមគោលការណ៍ទូទៅ នៃអនាម័យចំណីអាហារ និងបទបញ្ញត្តិនានាដែលតម្រូវដោយក្រសួងឧស្សាហកម្មរ៉ែ និងថាមពល សម្រាប់ជាប្រយោជន៍ដល់សុខភាព សុវត្ថិភាពសាធារណៈ និងបរិស្ថាន។
- បច្ចុប្បន្ននេះ អធិការកិច្ចត្រូវបានធ្វើឡើងដោយក្រុមមន្ត្រីអធិការកិច្ច មកពីនាយកដ្ឋានឧស្សាហកម្មខ្នាតតូច និងសិប្បកម្ម នាយកដ្ឋានកិច្ចការឧស្សាហកម្ម នាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម នាយកដ្ឋាននីតិកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។
- អាស្រ័យលើទំហំ និងភាពសាំញ៉ាំនៃខ្សែសង្វាក់ផលិតកម្ម អធិការកិច្ចលើកដំបូងជាធម្មតាមានរយៈពេលពី ៤ ទៅ ៨ ម៉ោង ចំណែកឯអធិការកិច្ចបន្ទាប់មកទៀតមានរយៈពេលតិចជាង ៣ ម៉ោង។
- ដើម្បីបង្កើនល្បឿននៃដំណើរការធ្វើអធិការកិច្ច សហគ្រាសត្រូវតែមានឯកសារពាក់ព័ន្ធ ដូចដែលបានរៀបរាប់ នៅក្នុងតារាងទី ៣ ព្រមទាំងរាល់ឯកសារកត់ត្រាណាដែលទាក់ទងទៅនឹងខ្សែសង្វាក់ផលិតកម្មរួចជាស្រេច។
- រហូតមកដល់ពេលបច្ចុប្បន្ននេះ មិនមានការបង់ថ្លៃលើអធិការកិច្ចរោងចក្រ និងសិប្បកម្មចំណីអាហារនោះទេ។ ភាពញឹកញាប់នៃការធ្វើអធិការកិច្ច គឺអាស្រ័យទៅលើកំរិតហានិភ័យរបស់សហគ្រាសក្នុងការធានានូវសុវត្ថិភាពចំណីអាហារ។ ក្រុមអធិការកិច្ចចុះត្រួតពិនិត្យសិប្បកម្មរបស់លោកអ្នកជារៀងរាល់ឆ្នាំ ក៏ប៉ុន្តែក្រុមនេះ អាចនឹងធ្វើការត្រួតពិនិត្យបន្ថែមនៅសិប្បកម្មរបស់លោកអ្នកដោយគ្មានការជូនដំណឹងជាមុន ប្រសិនបើមានពាក្យបណ្តឹង។

### ច្បាប់ និងបទបញ្ញត្តិគ្រប់គ្រងរោងចក្រ និងអធិការកិច្ចសិប្បកម្មមានដូចតទៅ:

- ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- ប្រកាសស្តីពីនីតិវិធី និងបែបបទសុំលិខិតអនុញ្ញាតបង្កើតរោងចក្រ-សិប្បកម្ម

## តារាង ៣៖ ច្បាប់ និង លក្ខខណ្ឌតម្រូវទាក់ទងនឹងអធិការកិច្ចរោងចក្រ និងសិប្បកម្ម កែច្នៃចំណីអាហារបន្ទាប់

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| **ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម** | | |
| 📖 ដើម្បីបង្កើតរោងចក្រ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ | ✍ ដាក់ពាក្យសុំលិខិតអនុញ្ញាតមុនពេលបង្កើតរោងចក្រ ។ | 🗎 លិខិតអនុញ្ញាតឱ្យបង្កើតរោងចក្រ ចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| 📖 ម្ចាស់រោងចក្រត្រូវបង្ហាញលិខិតអនុញ្ញាតឱ្យបង្កើត និងលិខិតអនុញ្ញាតផ្សេងទៀត នៅទីកន្លែងបើកចំហរសមរម្យមួយនៅក្នុងរោងចក្ររបស់ខ្លួន ដែលជាកន្លែងងាយស្រួលមើលឃើញ | ✍ ដាក់លិខិតអនុញ្ញាតទាំងអស់នៅទីកន្លែងបើកចំហរដែលងាយស្រួលមើលឃើញ ។ | |
| 📖 សិប្បកម្មត្រូវបានអនុញ្ញាតឱ្យបង្កើតឡើង និងដំណើរការបានលុះត្រាតែ ម្ចាស់សិប្បកម្មជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត/ក្រុង ។ | ✍ ជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន អំពីការបង្កើតសិប្បកម្មរបស់លោកអ្នក និងចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត/ក្រុង ។ | 🗎 លិខិតចុះបញ្ជី |
| **ប្រកាសលេខ ៦០៧ស្តីពីនីតិវិធី និងបែបបទសុំលិខិតអនុញ្ញាតបង្កើតរោងចក្រ-សិប្បកម្ម** | | |
| 📖 សិប្បកម្មទាំងអស់ដែលផលិត ឬនឹងផលិតផលិតផល ក្នុងបរិមាណអប្បបរមា ដូចដែលបានកំណត់ នៅក្នុងតារាងឧបសម្ព័ន្ធទី ២ ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មុនពេលបង្កើត និងចាប់ផ្តើមប្រតិបត្តិការ ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចធ្វើបច្ចុប្បន្នភាព និងកែប្រែបញ្ជីប្រភេទ សិប្បកម្មដែលតម្រូវសុំប្រកាសអនុញ្ញាត នៅក្នុងប្រកាសនេះ ។ | ✍ ប្រសិនបើសិប្បកម្មផលិតក្នុងបរិមាណច្រើនជាង ការកំណត់ក្នុងឧបសម្ព័ន្ធ ២A នោះសិប្បកម្មត្រូវស្នើសុំលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ | 🗎 លិខិតអនុញ្ញាតធ្វើអាជីវកម្ម ចេញដោយក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល |

## រូបទី ២: នីតិវិធីនៃការធ្វើអធិការកិច្ចរោងចក្រ និងសិប្បកម្ម

**ជំហាន ១** ការបើកកិច្ចប្រជុំ

- ក្រុមអធិការកិច្ចបង្ហាញអត្តសញ្ញាណប័ណ្ណ និងបង្ហាញលិខិតបេសកកម្ម
- ម្ចាស់ ឬអ្នកគ្រប់គ្រងបង្ហាញអាជ្ញាប័ណ្ណឱ្យបើកអាជីវកម្ម វិញ្ញាបនប័ត្រវិភាគសំណាកពីមុន និងកំណត់ត្រាផលិតកម្ម ប្រសិនបើមាន

**ជំហាន ២** ការពិនិត្យមើលគំនូសបំព្រួញខ្សែសង្វាក់ផលិតកម្ម

**ជំហាន ៣** ការដើរមើល ខ្សែសង្វាក់ផលិតកម្ម

- ការវាយតំលៃបរិវេណជុំវិញ
- កំណត់ត្រាបណ្តុះបណ្តាលបុគ្គលិក
- ការវាយតំលៃវត្ថុធាតុដើម
- ការវាយតំលៃលើគ្រឿងបរិក្ខារ និងឧបករណ៍
- ការទប់ស្កាត់សត្វល្អិតចង្រៃ
- ការដឹកជញ្ជូន រក្សាទុក និងប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់
- រក្សាទុកសំរាម និងកំទេចចោល

**ជំហាន ៤** កិច្ចប្រជុំបញ្ចប់

- ពិភាក្សាអំពីលទ្ធផល ( ជាពិសេសអ្វីដែលមិនអនុលោម)
- យល់ព្រមតាមពេលវេលាសម្រាប់សកម្មភាពកែតម្រូវ ប្រសិនបើមាន
- សរសេររបាយការណ៍អធិការកិច្ច
- ចុះហត្ថលេខាលើរបាយការណ៍កិច្ចប្រជុំ
- ពិភាក្សាលើការកែលម្អដែលអាចធ្វើបាន

**ជំហាន ៥**

អធិការកិច្ចតាមដាន

**សំគាល់:** អធិការកិច្ចធ្វើឡើងដោយក្រុមមកពីនាយកដ្ឋាន ឧស្សាហកម្មខ្នាតតូច និងសិប្បកម្ម នាយកដ្ឋានកិច្ចការឧស្សាហកម្ម នាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម និងនាយកដ្ឋាននីតិកម្ម របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

តារាង ៤: ការណែនាំសម្រាប់អធិការកិច្ចលើសុវត្ថិភាពចំណីអាហារ និងគេសជ្ជៈ

| ដំណាក់ | ការណែនាំ |
|---|---|
| ជំហានទី ១ | ▪ ដើម្បីជៀសវាងមន្ត្រីអធិការកិច្ចដែលគ្មានការអនុញ្ញាតមកត្រួតពិនិត្យសហគ្រាស សូមសួររកប័ណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ច និងលិខិតបេសកកម្មដែលចេញដោយ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។<br>▪ រោងចក្រត្រូវមានអាជ្ញាប័ណ្ណធ្វើអាជីវកម្ម លិខិតបញ្ជាក់ការវិភាគសំណាកផលិតផល និងកំណត់ត្រាផលិតកម្មត្រៀមជាស្រេចសម្រាប់មន្ត្រីអធិការកិច្ចពិនិត្យ ប្រសិនបើមាន ។ |
| ជំហានទី ២ | ▪ រោងចក្រត្រូវមានគំនូសបំព្រួញខ្សែសង្វាក់ផលិតកម្មត្រៀមរួចជាស្រេច ។ ប្រសិនបើមិនមាន រោងចក្រចាំបាច់ត្រូវរៀបចំបង្កើតគំនូសបំព្រួញនោះមុនពេលអធិការកិច្ច ។ |
| ជំហានទី ៣ | ▪ រោងចក្រត្រូវត្រៀមខ្លួនសំរាប់អធិការកិច្ច អ្នកតំណាងរោងចក្រត្រូវដើរអមជាមួយនឹងមន្ត្រីអធិការកិច្ចក្នុងអំឡុងពេលដើរមើលខ្សែសង្វាក់ផលិតកម្ម ព្រោះពួកគាត់រកឃើញថាមានបញ្ហាណាមួយដែលត្រូវការឱ្យលោកអ្នកបកស្រាយបញ្ជាក់ ។ |
| ជំហានទី ៤ | ▪ ប្រសិនបើមន្ត្រីអធិការកិច្ចរកឃើញភាពមិនអនុលោម ត្រូវសួរមន្ត្រីអធិការកិច្ចឱ្យបកស្រាយបញ្ជាក់អំពីបញ្ហាមិនអនុលោម ដើម្បីអាចចាត់វិធានការដើម្បីអនុលោម<br>▪ ប្រសិនបើលោកអ្នកមិនសូវប្រាកដថាត្រូវដោះស្រាយយ៉ាងដូចម្តេចជាមួយនឹងភាពមិនអនុលោមនោះ ត្រូវសុំការណែនាំពីមន្ត្រីអធិការកិច្ច<br>▪ ត្រូវធ្វើឱ្យប្រាកដថាពេលវេលាដែលផ្តល់ឱ្យដោយមន្ត្រីអធិការកិច្ចមានរយៈពេលគ្រប់គ្រាន់សម្រាប់ចាត់វិធានការកែតម្រូវ<br>▪ អានរបាយការណ៍អធិការកិច្ចឱ្យបានហ្មត់ចត់ មុនពេលចុះហត្ថលេខា |
| ជំហានទី ៥ | ▪ ត្រូវប្រាកដថាពេលវេលាដែលបានព្រមព្រៀងសម្រាប់សកម្មភាពកែតម្រូវ ត្រូវបានបំពេញទាន់ពេលវេលា |

## ២.២ ការចុះបញ្ជី លិខិតបញ្ជាក់សញ្ញាស្តង់ដារ និងការបិទស្លាកសញ្ញា ផលិតផលចំណីអាហារដែលវេចខ្ចប់រួច

- ច្បាប់ស្តីពីស្តង់ដារកម្ពុជា
- ប្រកាសលេខ ៩៦៣ ស្តីពីការចុះបញ្ជីផលិតផលឧស្សាហកម្ម និង
- ប្រកាសលេខ ១០៤៥ ស្តីពីស្តង់ដាកម្ពុជា CS 00១-២000:ការបិទស្លាកសញ្ញាលើផលិតផលចំណីអាហារ ។

**កំណត់សំគាល់:** ជាចំណីអាហារវេចខ្ចប់រួច ឬផលិតរួចដាក់ក្នុងសំបកវេចខ្ចប់ត្រៀមជាស្រេចសម្រាប់លក់ ឬ ដឹកជញ្ជូនជូនអតិថិជន ។

## តារាង ៥: ច្បាប់ ប្រកាស និងលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការចុះបញ្ជីវិញ្ញាបនប័ត្រ ផលិតផល និងការបិទស្លាកសញ្ញាផលិតផល

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| **ច្បាប់ស្តីពីស្តង់ដារកម្ពុជា** | | |
| 🕮 នៅពេលដែលស្តង់ដារបញ្ជាមួយត្រូវបានប្រកាស និងក្រោយកាលបរិច្ឆេទចូលជាធរមានដែលកំណត់នៅក្នុងប្រកាសនោះ ការផលិតឬការបន្តផលិត នូវផលិតផលណាមួយ ឬការរៀបចំខ្សែសង្វាក់ផលិតកម្មណាមួយត្រូវអនុលោមតាមស្តង់ដារបញ្ជានោះ ។ | ✍ ប្រសិនបើផលិតផលស្ថិតនៅក្នុងស្តង់ដារបញ្ជា[៣] ផលិតផលត្រូវអនុលោមតាមស្តង់ដារ នៅវិទ្យាស្ថានស្តង់ដារកម្ពុជា (នីតិវិធីដើម្បីទទួលបានវិញ្ញាបនប័ត្របង្ហាញនៅក្នុងរូបទី ៣)<br>✍ នៅក្នុងករណីដែលពាក្យស្នើសុំត្រូវបាន បដិសេធដោយវិទ្យាស្ថាននោះ អាជីវកម្មអាចធ្វើការតវ៉ានឹងការបដិសេធនេះ ទៅរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ ។ | 🗎 វិញ្ញាបនប័ត្រផលិតផល<br>🗎 លិខិតសម្រេចចុងក្រោយពីរដ្ឋមន្ត្រី |
| 🕮 ប្រសិនបើអាជ្ញាប័ណ្ណត្រូវបាត់ ឬខូចខាតទាំងស្រុងនោះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណទុតិយតាទៅវិទ្យាស្ថានក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលដឹងឮជាសាធារណៈ ។ | ✍ ប្រសិនបើអាជ្ញាប័ណ្ណរបស់លោកអ្នកបាត់ ឬខូចខាត លោកអ្នកត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណទុតិយតាជាបន្ទាន់ ។ | 🗎 អាជ្ញាប័ណ្ណទុតិយតា |
| 🕮 វិទ្យាស្ថានមានសិទ្ធិព្យួរអាជ្ញាប័ណ្ណក្នុងរយៈពេលមួយមិនឱ្យលើសពី ៣ខែ ក្នុងមួយលើក នៅពេលដែលរកឃើញថាអ្នកកាន់អាជ្ញាប័ណ្ណរំលោភទៅនឹងបញ្ញត្តិនៃច្បាប់នេះ ឬ បទបញ្ជាដែលក្រសួងបានចេញស្របតាមច្បាប់នេះ ឬលក្ខខណ្ឌដែលបានដាក់ជាបញ្ញត្តិដោយវិទ្យាស្ថាន ឬ រកឃើញថាផលិតផលនោះមិនអនុលោមទៅតាមស្តង់ដាដែលបានកំណត់ ។ | ✍ ប្រសិនបើវិទ្យាស្ថានផ្អាក ឬដកហូតអាជ្ញាប័ណ្ណ ក្រុមហ៊ុនអាចៈ<br>▪ អនុវត្តតាមសេចក្តីជូនដំណឹងអំពីហេតុផលនៃការផ្អាក ឬដកហូត ឬក៏<br>▪ តវ៉ានឹងការផ្អាក ឬការដកហូតនេះ ជាលាយល័ក្ខអក្សរទៅកាន់រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | |

[៣] បច្ចុប្បន្ននេះមានស្តង់ដារបញ្ជាសំរាប់ផលិតផល ៤ ប្រភេទ: ទឹកពិសាដប ទឹកខ្មេះ ទឹកម្ទេស និងទឹកស៊ីអ៊ីវ

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| នៅពេលដែលអាជ្ញាប័ណ្ណសំរាប់ផលិតផលណាមួយត្រូវបានព្យួរ អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវបញ្ជាក់តាមរូបភាពណាមួយ ដែលបង្ហាញថា ផលិតផលនោះនៅមានអាជ្ញាប័ណ្ណនោះទេ ។ | ប្រសិនបើអាជ្ញាប័ណ្ណសម្រាប់ប្រើសញ្ញាស្តង់ដារ របស់លោកអ្នកត្រូវបានផ្អាក លោកអ្នកមិនត្រូវប្រើស្លាកសញ្ញាស្តង់ដារ ឬទម្រង់ណាមួយដែលបង្ហាញថា ផលិតផលនេះនៅតែទទួលបានអាជ្ញាប័ណ្ណ នោះឡើយ ។ | |
| ប្រកាសលេខ ៩៦៣ ស្តីពីការចុះបញ្ជីផលិតផលឧស្សាហកម្ម | | |
| ដើម្បីធានាការបិទស្លាកផលិតផលឧស្សាហកម្ម អោយបានត្រឹមត្រូវតាមស្តង់ដាររបស់រដ្ឋ និងដើម្បីទប់ស្កាត់ ការលក់ផលិតផលក្លែងបន្លំ ក្រុមហ៊ុន រោងចក្រ សហគ្រាស និង សិប្បកម្មទាំងអស់រួមទាំងផលិតផលនាំចូល ត្រូវយកផលិតផលរបស់ខ្លួន មកចុះបញ្ជីផលិតផលនៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល មុននឹងធ្វើចរាចរលក់ផលិតផលនៅលើទីផ្សារក្នុងកម្ពុជា | ប្រសិនបើផលិតផលមិនស្ថិតក្នុងស្តង់ដាបញ្ជាទេ សូមចុះបញ្ជីផលិតផលរបស់លោកអ្នកនៅ វិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មុនពេល ដាក់លក់នៅលើទីផ្សារ ។ នីតិវិធីនៃការចុះបញ្ជីផលិតផលត្រូវបានរៀបរាប់នៅក្នុងរូបទី ៤ ។ | អាជ្ញាប័ណ្ណសំរាប់ប្រើសញ្ញាចុះបញ្ជីផលិតផល |
| ប្រកាសលេខ ១០៤៥ ស្តីពីស្តង់ដារកម្ពុជា CS ០០១-២០០០ ការបិទស្លាកលើផលិតផលចំណីអាហារវេចខ្ចប់រួច | | |
| ក្រុមហ៊ុន សហគ្រាស និង សិប្បកម្មទាំងអស់ត្រូវបិទស្លាកសញ្ញាលើចំណីអាហារដែលវេចខ្ចប់រួចដោយអនុលោមតាមស្តង់ដា CS០០១-២០០០ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាស | ក្រុមហ៊ុន សហគ្រាសឬសិប្បកម្មរបស់លោកអ្នកត្រូវបិទស្លាកសញ្ញាលើចំណីអាហារដែលវេចខ្ចប់រួចដោយមាន :<br>▪ ឈ្មោះចំណីអាហារ<br>▪ ពាណិជ្ជសញ្ញា<br>▪ បញ្ជីគ្រឿងផ្សំ<br>▪ បរិមាណសុទ្ធ ឬទម្ងន់សុទ្ធ<br>▪ ឈ្មោះ និងអាសយដ្ឋានរបស់ក្រុមហ៊ុន សហគ្រាស ឬ សិប្បកម្ម<br>▪ ប្រទេសដើមកំណើតផលិតផល<br>▪ លេខឡូត៍ផលិតផល<br>▪ កាលបរិច្ឆេទផលិត និងការណែនាំពីការរក្សាទុក<br>▪ ត្រូវសរសេរជាភាសាខ្មែរ ប្រសិនបើផលិតផលសម្រាប់ប្រើប្រាស់ក្នុងប្រទេស | ស្លាកសញ្ញាផលិតផល |

## អាជ្ញាប័ណ្ណសម្រាប់ការប្រើសញ្ញាស្តង់ដារកម្ពុជា

- គោលបំណងរបស់អាជ្ញាប័ណ្ណសម្រាប់ការប្រើសញ្ញាស្តង់ដារកម្ពុជា គឺដើម្បីធានាថាផលិតផល ឬលក្ខខណ្ឌ ផលិតកម្មបានអនុលោមតាមស្តង់ដារបញ្ជោរបស់កម្ពុជា ចំពោះផលិតផល ក៏ដូចជាធានាដល់សុខភាពសាធារណៈ ។
- បច្ចុប្បន្ននេះ ផលិតផលដែលស្ថិតនៅក្នុងស្តង់ដារបញ្ជោមាន : ទឹកពិសាដប ទឹកខ្មេះ ទឹកម្ទេស និងទឹកស៊ីអ៊ីវ ។ សម្រាប់ព័ត៌មានថ្មីៗ សូមចូលទៅកាន់គេហទំព័ររបស់វិទ្យាស្ថានស្តង់ដារកម្ពុជា: http://www.isc.gov.kh/listCambodiaStandard.php
- មន្ត្រីអធិការកិច្ច មកពីនាយកដ្ឋានវិញ្ញាបនប័ត្រកម្មនៃវិទ្យាស្ថានស្តង់ដារកម្ពុជា នឹងអនុវត្តអធិការកិច្ចពេញលេញ ដែលជាទូទៅមានរយៈពេល ៣ ឬ ៤ ម៉ោងនៅបរិវេនទីតាំងផលិតកម្មរបស់លោកអ្នក នៅពេលណាដែលការដាក់ពាក្យស្នើសុំរបស់លោកអ្នកមានគ្រប់គ្រាន់ ។ អធិការកិច្ចលើកក្រោយ (អធិការកិច្ចមួយផ្នែក និងការប្រមូលសំណាក) ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា សម្រាប់ការប្រើអាជ្ញាប័ណ្ណសញ្ញាស្តង់ដារកម្ពុជា មានរយៈពេលតិចជាង ២ម៉ោង ។

## រូបទី ៣: នីតិវិធីនៃការធ្វើអធិការកិច្ចដើម្បីទទួលបានអាជ្ញាប័ណ្ណសម្រាប់ការប្រើសញ្ញាស្តង់ដារកម្ពុជា




សំគាល់: អធិការកិច្ចធ្វើឡើងដោយ នាយកដ្ឋានវិញ្ញាបនប័ត្រកម្មរបស់វិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល

## តារាង ៦: ការណែនាំដើម្បីទទួលបានអាជ្ញាប័ណ្ណប្រើសញ្ញាស្តង់ដារកម្ពុជា

| ជំហាន | ការណែនាំ |
|---|---|
| ជំហានទី ១ | ដាក់ពាក្យសុំ |
| | ▪ ទៅវិទ្យាស្ថានស្តង់ដារកម្ពុជា និងបំពេញពាក្យសុំ (សូមមើលឧបសម្ព័ន្ធ ២ B) |
| ជំហានទី ២ | ពិនិត្យមើលពាក្យសុំ |
| | ▪ សួរមន្ត្រីទទួលខុសត្រូវ តើឯកសារយោងមានគ្រប់គ្រាន់ និងត្រឹមត្រូវហើយឬនៅ<br>▪ ប្រសិនបើមិនទាន់មានគ្រប់គ្រាន់ តើនៅខ្វះឯកសារអ្វីទៀត |
| ជំហានទី ៣ | អធិការកិច្ចដំបូង ការយកគំរូផលិតផល និងការធ្វើតេស្ត |
| | ▪ បង់ថ្លៃអធិការកិច្ចដំបូង ការយកគំរូផលិតផល និងការធ្វើតេស្ត<br>▪ ក្រុមមន្ត្រីអធិការកិច្ចនឹងជូនដំណឹងដល់លោកអ្នកពីកាលបរិច្ឆេទដែលអធិការកិច្ច ការយកគំរូផលិតផល និងការធ្វើតេស្តត្រូវធ្វើឡើង |
| ជំហានទី ៤ | លទ្ធផលនៃអធិការកិច្ចដំបូង ការយកគំរូផលិតផល និងការធ្វើតេស្ត |
| | ▪ សួររករបាយការណ៍អធិការកិច្ច និងការធ្វើតេស្តលើផលិតផល<br>▪ ប្រសិនបើលទ្ធផលមិនជាទីពេញចិត្តទេ មន្ត្រីមកពីវិទ្យាស្ថានស្តង់ដារកម្ពុជានឹងផ្តល់ជំនួយបច្ចេកទេស |
| ជំហានទី ៥ | ការវាយតម្លៃលើប្រព័ន្ធធានាគុណភាព និងយកគំរូផលិតផល និងធ្វើតេស្តជាលើកទីពីរ |
| | ▪ បង់ថ្លៃអធិការកិច្ចប្រព័ន្ធធានាគុណភាព យកគំរូផលិតផលលើកទីពីរ និងធ្វើតេស្ត<br>▪ ក្រុមមន្ត្រីអធិការកិច្ចនឹងជូនដំណឹងដល់លោកអ្នកពីកាលបរិច្ឆេទការវាយតម្លៃ ការយកគំរូផលិតផល និងការធ្វើតេស្តត្រូវធ្វើឡើង |
| ជំហានទី ៦ | លទ្ធផល |
| | ▪ សួររករបាយការណ៍អធិការកិច្ច និងការធ្វើតេស្តលើផលិតផល |
| ជំហានទី ៧ | ចុះហត្ថលេខាលើកិច្ចព្រមព្រៀងឱ្យប្រើសញ្ញាស្តង់ដារកម្ពុជា |
| | ▪ បង់ថ្លៃ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀង (សូមមើលតារាងឧបសម្ព័ន្ធ ២ C ) |
| ជំហានទី ៨ | ផ្តល់អាជ្ញាប័ណ្ណឱ្យប្រើសញ្ញាស្តង់ដារកម្ពុជា |
| | ▪ បន្ទាប់ពីបង់ថ្លៃហើយ អាជ្ញាប័ណ្ណឱ្យប្រើសញ្ញាស្តង់ដារកម្ពុជានឹងត្រូវផ្តល់ឱ្យ (សូមមើលឧបសម្ព័ន្ធ ២ E)។ |
| ជំហានទី ៩ | ការយកគំរូផលិតផល |
| | ▪ កិច្ចព្រមព្រៀងដែលបានចុះហត្ថលេខានៅក្នុងជំហានទី៧ នឹងអនុញ្ញាតឱ្យក្រុមមន្ត្រីអធិការកិច្ចរបស់ ISC ធ្វើអធិការកិច្ច និងយកគំរូផលិតផលនៅសហគ្រាសរៀងរាល់៣ខែម្តង |

## អាជ្ញាប័ណ្ណសម្រាប់ការប្រើសញ្ញាចុះបញ្ជីផលិតផល

- គោលបំណងរបស់អាជ្ញាប័ណ្ណសម្រាប់ការប្រើសញ្ញាចុះបញ្ជីផលិតផល គឺដើម្បីធានាថាផលិតផល ឬលក្ខខណ្ឌផលិតកម្ម ត្រូវបានអនុលោមតាមប្រកាស CS00១ : ២000 ក៏ដូចជាធានាដល់សុខភាពសាធារណៈ ។
- ផលិតផលទាំងអស់ដែលមិនស្ថិតនៅក្នុងស្តង់ដារបញ្ជា ត្រូវតែចុះបញ្ជីនៅវិទ្យាស្ថានស្តង់ដារកម្ពុជា
- នៅពេលដែលពាក្យស្នើសុំ មានព័ត៌មានគ្រប់គ្រាន់ មន្ត្រីអធិការកិច្ចមកពីនាយកដ្ឋានបញ្ជាក់កម្ម និងវាយតម្លៃទទួលស្គាល់នៃវិទ្យាស្ថានស្តង់ដារកម្ពុជា នឹងធ្វើអធិការកិច្ចពេញលេញ ដែលជាទូទៅមានរយៈពេលពី ៣ ទៅ ៤ម៉ោង នៅទីតាំងរបស់រោងចក្រ ឬសិប្បកម្ម ។ អធិការកិច្ចបន្ទាប់ (អធិការកិច្ចមួយផ្នែក និងការយកគំរូផលិតផល) ដោយផ្អែកទៅលើកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ដែលជាផ្នែកមួយនៃអាជ្ញាប័ណ្ណ សម្រាប់ការប្រើសញ្ញាចុះបញ្ជីផលិតផល ជាទូទៅមានរយៈពេលតិចជាង ២ ម៉ោង ។
- ដើម្បីកាត់បន្ថយរយៈពេលអធិការកិច្ច រោងចក្រ ឬសិប្បកម្មគួរតែមានឯកសារពាក់ព័ន្ធ ដូចដែលបានរៀបរាប់នៅក្នុងតារាង ទី ៥ និងបណ្តាកំណត់ត្រាដែលទាក់ទងនឹងខ្សែសង្វាក់ផលិតកម្ម ត្រៀមជាស្រេច ។

## រូបទី ៤: នីតិវិធីអធិការកិច្ចដើម្បីទទួលបានអាជ្ញាប័ណ្ណសំរាប់ប្រើសញ្ញាចុះបញ្ជីផលិតផល




**សំគាល់:** អធិការកិច្ចធ្វើឡើងដោយ នាយកដ្ឋានបញ្ញត្តិកម្ម និងវាយតំលៃទទួលស្គាល់នៃវិទ្យាស្ថានស្តង់ដារកម្ពុជា

### តារាង ៧: ការណែនាំដើម្បីទទួលបានអាជ្ញាប័ណ្ណប្រើសញ្ញាចុះបញ្ជីផលិតផល

| ជំហាន | ការណែនាំ |
|---|---|
| ជំហានទី ១ | ដាក់ពាក្យសុំ |
| | ▪ បំពេញពាក្យសុំចុះបញ្ជីនៅវិទ្យាស្ថានស្តង់ដារកម្ពុជា ដោយភ្ជាប់ជាមួយនូវឯកសារយោងចាំបាច់ |
| ជំហានទី ២ | ពិនិត្យមើលពាក្យសុំ |
| | ▪ ធានាថាពាក្យសុំ និងមានឯកសារភ្ជាប់គ្រប់គ្រាន់ និងត្រឹមត្រូវ |
| ជំហានទី ៣ | ការយកសំណាកផលិតផល និងធ្វើតេស្តជំហានដំបូង |
| | ▪ បង់ថ្លៃសំរាប់ការរៀបចំយកគំរូផលិតផល និងធ្វើតេស្តជំហានដំបូង<br>▪ ក្រុមការងារអធិការកិច្ចនឹងជូនដំណឹងដល់អ្នកថាពេលណានឹងត្រូវយកគំរូផលិតផល និងធ្វើតេស្ត |
| ជំហានទី ៤ | លទ្ធផលធ្វើតេស្ត |
| | ▪ សួររករបាយការណ៍អធិការកិច្ច និងលទ្ធផលនៃការធ្វើតេស្ត |
| ជំហានទី ៥ | ការយកសំណាកផលិតផល និងការធ្វើតេស្តលើកទី២ |
| | ▪ បង់ថ្លៃសំរាប់ការយកគំរូ និងការធ្វើតេស្តលើកទី២<br>▪ ក្រុមការងារអធិការកិច្ចនឹងជូនដំណឹង ថាពេលណានឹងត្រូវយកគំរូផលិតផល និងធ្វើតេស្ត |
| ជំហានទី ៦ | លទ្ធផល |
| | ▪ សួររករបាយការណ៍អធិការកិច្ច និងលទ្ធផលនៃការធ្វើតេស្ត |
| ជំហានទី ៧ | ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងដើម្បីប្រើសញ្ញាចុះបញ្ជីផលិតផល |
| | ▪ បង់ថ្លៃសេវា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀង (សូមមើលតារាងឧបសម្ព័ន្ធ ២ C)។ |
| ជំហានទី ៨ | ការចេញវិញ្ញាបនប័ត្រផលិតផល និងអាជ្ញាប័ណ្ណសំរាប់ប្រើសញ្ញាចុះបញ្ជីផលិតផល |
| | ▪ បន្ទាប់ពីការបង់ថ្លៃរួចហើយ អាជ្ញាប័ណ្ណនឹងត្រូវចេញឱ្យប្រើប្រាស់ ហើយអ្នកអាចប្រើសញ្ញាចុះបញ្ជីបាន (សូមមើលតារាងឧបសម្ព័ន្ធ ២ F)។ |
| ជំហានទី ៩ | ការយកសំណាកផលិតផល |
| | ▪ កិច្ចព្រមព្រៀងដែលបានចុះហត្ថលេខានៅជំហានទី៧ អនុញ្ញាតឱ្យក្រុមការងារអធិការកិច្ចរបស់វិទ្យាស្ថានស្តង់ដារកម្ពុជាធ្វើអធិការកិច្ច និងយកគំរូផលិតផលនៅសហគ្រាសរបស់អ្នករៀងរាល់បីខែម្តង។ |

# អធិការកិច្ចលើការគ្រប់គ្រងបរិស្ថាន

ច្បាប់ និងអនុក្រឹត្យខាងក្រោមនេះ មិនមែនសំរាប់អនុវត្តលើសហគ្រាសរបស់អ្នកទាំងអស់ទេ។ វាអាស្រ័យលើទំហំ និងប្រភេទនៃសំណល់ដែលសហគ្រាសរបស់អ្នកបញ្ចេញចោល។ ប្រសិនបើសហគ្រាសរបស់អ្នកបញ្ចេញទឹកស្អុយលើសពី ១០ម$^{៣}$/ថ្ងៃ បញ្ចេញសំលេងលើសពី ៧០ dB(A) (ដេស៊ីបែល) នៅពេលថ្ងៃ និង ៥០ dB(A) នៅពេលយប់ សំណល់ប្រកបដោយគ្រោះថ្នាក់ (សារធាតុហ្វេណុល វិទ្យុសកម្ម អេទែរ។ល។) សហគ្រាសរបស់អ្នកត្រូវសុំការអនុញ្ញាត។ ក្នុងករណីសហគ្រាសមិនទទួលបាន ការអនុញ្ញាតសហគ្រាសអាចទទួលការផាកពិន័យ ឬផ្អាកសកម្មភាពបើប្រព្រឹត្តល្មើសធ្ងន់ធ្ងរ។

### ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងបទបញ្ញត្តិមានដូចខាងក្រោម:

- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- អនុក្រឹត្យលេខ ២៧ ស្តីពីការត្រួតពិនិត្យការបំពុលទឹក
- អនុក្រឹត្យលេខ ៤២ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង
- អនុក្រឹត្យលេខ ៣៦ ស្តីពីការគ្រប់គ្រងសំណល់រឹង និង
- អនុក្រឹត្យលេខ ៧២ ស្តីពីដំណើរការវាយតំលៃផលប៉ះពាល់បរិស្ថាន

## តារាង ៨: ច្បាប់ និងអនុក្រឹត្យដែលពាក់ព័ន្ធនឹងអធិការកិច្ចគ្រប់គ្រងបរិស្ថាន

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| **ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ** | | |
| 🕮 ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន និងការទទួលខុសត្រូវ លើតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថាន សហការជាមួយក្រសួងពាក់ព័ន្ធនានា អាចចូលធ្វើអធិការកិច្ច ក្នុងតំបន់ ទីក្នុងបរិវេណអគារ នៅលើឬក្នុងមធ្យោបាយដឹកជញ្ជូនសំណល់រាវផ្សេងៗ ប្រសិនបើក្រសួងបរិស្ថានពិនិត្យឃើញថាប្រភពទាំងនោះធ្វើឱ្យមានការប៉ះពាល់ដល់គុណភាពបរិស្ថាន ។<br><br>មន្ត្រីរបស់ក្រសួងបរិស្ថាន និងមន្ត្រីរបស់ក្រសួងពាក់ព័ន្ធដែលសហការជាមួយ ត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មមុននឹងធ្វើអធិការកិច្ច ។ នៅពេលធ្វើអធិការកិច្ចកាលណាពិនិត្យឃើញថាមានបទល្មើសកើតឡើង មន្ត្រីអធិការកិច្ចត្រូវរាយការណ៍ជាបន្ទាន់ទៅកាន់ស្ថាប័នមានសមត្ថកិច្ចដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។ | ✍ ដើម្បីជៀសវាងការធ្វើអធិការកិច្ចដោយគ្មានការអនុញ្ញាត ត្រូវធានាថាមន្ត្រីអធិការកិច្ចមាន អត្តសញ្ញាណប័ណ្ណ និងលិខិតបេសកកម្ម ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធត្រឹមត្រូវ ។<br><br>✍ អនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចធ្វើអធិការកិច្ចនៅទីតាំងរោងចក្រ ឬសិប្បកម្ម ប្រសិនបើអត្តសញ្ញាណប័ណ្ណ និងលិខិតបេសកកម្ម របស់គេពិតជាត្រឹមត្រូវ និងមានសុពលភាព ។ | 🗎 កត់ឈ្មោះ តួនាទីស្ថាប័ន អត្តសញ្ញាណប័ណ្ណ លេខលិខិតបេសកកម្ម និងហត្ថលេខារបស់ពួកគេនៅក្នុងសៀវភៅកំណត់ត្រា ។ |
| **អនុក្រឹត្យលេខ ២៧ ស្តីពីការត្រួតពិនិត្យការបំពុលទឹក** | | |
| 🕮 ប្រភេទនៃសំណល់រាវដែលបញ្ចេញដោយក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវទៅទីកន្លែងដទៃទៀត ដូចមានចែងនៅក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះនៅក្នុងឧបសម្ព័ន្ធ ៣ នៃអនុក្រឹត្យនេះ ហើយដែលចែកចេញជាពីរប្រភេទដូចខាងក្រោម៖ (សូមមើលឧបសម្ព័ន្ធ ៣ A) | ✍ ប្រសិនបើសហគ្រាសរបស់អ្នកស្ថិតនៅក្នុងប្រភេទទី១ ហើយបញ្ចេញសារធាតុលើសពី ១០ម$^3$/ថ្ងៃ អ្នកត្រូវសុំការអនុញ្ញាត ពីក្រសួងបរិស្ថានជាមុន (៣០ថ្ងៃ នៅរាជធានីភ្នំពេញ និង៤០ថ្ងៃនៅតាមខេត្ត) ។ | 🗎 លិខិតអនុញ្ញាតដែលចេញដោយក្រសួងបរិស្ថាន |

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| 🕮 ដើម្បីអាចបញ្ចេញចោលនូវសំណល់រាវប្រភេទទី១ សហគ្រាសត្រូវមានការអនុញ្ញាតជាមុនពី ក្រសួងបរិស្ថាន ក្នុងករណីដែល បរិមាណនៃការបញ្ចេញលើសពី១០ម៉ែតគូបក្នុងមួយថ្ងៃ (១០ម៣/ថ្ងៃ) ប៉ុន្តែបរិមាណនេះ មិនគិតបញ្ចូលបរិមាណទឹក ដែលប្រើសំរាប់ប្រពន្ធ័ត្រជាក់គ្រឿងចក្រ ។<br>🕮 ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលដែលមានបំណងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវ ទៅកាន់ទីកន្លែងផ្សេងទៀត ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថានៈ<br>▪ សែសិបថ្ងៃ (៤០ ថ្ងៃ) មុនចាប់ផ្តើមបញ្ចេញសំណល់រាវរាជធានីភ្នំពេញ និងហុកសិប ថ្ងៃ (៦០ ថ្ងៃ) សំរាប់ថ្មីនៅតាមបណ្តាខេត្ត និងទីក្រុងផ្សេងៗ ។<br>▪ ក្នុងអំឡុងពេលសាមសិបថ្ងៃ (៣០ ថ្ងៃ) បន្ទាប់ពីមានការស្នើសុំពីក្រសួងបរិស្ថាន សំរាប់បញ្ចេញសំណល់រាវដែលមានស្រាប់នៅរាជធានីភ្នំពេញ និងសែសិបថ្ងៃ (៤០ថ្ងៃ) សំរាប់សំណល់រាវថ្មីនៅតាមបណ្តាខេត្ត និងទីក្រុងផ្សេងៗ ។ | | |
| **អនុក្រិត្យលេខ៤២ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង** | | |
| 🕮 ហាមឃាត់ដាច់ខាតការបង្កឱ្យមានសំលេង ដែលលើសពីកំរិតស្តង់ដារដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ។ | ✍ ការបញ្ចេញសំលេងពីសហគ្រាសរបស់អ្នកមិនត្រូវលើសពីកំរិតស្តង់ដារដែលបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធ ៣ B ទេ ប្រសិនបើ សហគ្រាសមានទីតាំងនៅតំបន់សាធារណៈ និងតំបន់រស់នៅ សហគ្រាសមិនត្រូវបញ្ចេញលើសពីកំរិតស្តង់ដារនៅក្នុងឧបសម្ព័ន្ធ ៣ C បើសហគ្រាសនោះស្ថិតនៅក្នុងតំបន់រោងចក្រឧស្សាហកម្ម ។ | |

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| **អនុក្រឹត្យលេខ ៣៦ ស្តីអំពីសំណល់រឹង** | | |
| 🕮 អ្នកផលិតសំណល់រឹង ត្រូវទទួលខុសត្រូវក្នុងការស្តុកសំណល់ទាំងនោះជាបណ្តោះអាសន្នតាមរបៀបដែលមានសុវត្ថិភាព និងសមស្រប | ✍ ប្រសិនសហគ្រាសផលិតសំណល់រឹងដូចបានចែងក្នុងឧបសម្ព័ន្ធ ៣ D សហគ្រាសនោះត្រូវចាត់ចែងសំណល់ទាំងនោះតាមរបៀបមានសុវត្ថិភាព | |
| 🕮 សហគ្រាសដែលបញ្ចេញសំណល់រឹងត្រូវរៀបចំរបាយការណ៍សំណល់រឹងប្រចាំត្រីមាស និងដាក់ឱ្យក្រសួងបរិស្ថានត្រួតពិនិត្យ ។ របាយការណ៍រួមមានៈ<br>▪ ប្រភេទ និងបរិមាណសំណល់<br>▪ វិធីស្តុកទុកជាបណ្តោះអាសន្ន និង<br>▪ វិធីប្រើក្នុងកែច្នៃ និងចោលសំណល់រឹង | ✍ សហគ្រាសត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសអំពីការចោលសំណល់រឹងដូចការកំណត់របស់ក្រសួងបរិស្ថាន | |
| 🕮 ហាមដាច់ខាត ការបោះចោលនូវសំណល់ដែលមានគ្រោះថ្នាក់ទៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភព ឬបណ្តាញផ្លូវទឹក តំបន់ជនបទនិងតំបន់ព្រៃភ្នំ ។ | ✍ អ្នកមិនត្រូវ បោះចោលនូវសំណល់ដែលមានគ្រោះថ្នាក់ ទៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភព ឬបណ្តាញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំទេ ។ | |
| **អនុក្រឹត្យលេខ ៧២ ស្តីអំពីដំណើរការវាយតំលៃផលប៉ះពាល់បរិស្ថាន** | | |
| 🕮 សហគ្រាសដែលកំពុងដំណើរការទាំងអស់ត្រូវតែចងក្រងរបាយការណ៍វាយតំលៃផលប៉ះពាល់បរិស្ថានរបស់ខ្លួន រួចបញ្ជូនទៅក្រសួងបរិស្ថានដើម្បីពិនិត្យមើលឡើងវិញ និងអនុម័តលើសកម្មភាពដែលកំពុងដំណើរការ ដែលសកម្មភាពទាំងនោះត្រូវបានអនុញ្ញាតពីមុនដោយក្រសួង/ស្ថាប័នផ្សេង ។ | ✍ ប្រសិនបើសហគ្រាសរបស់អ្នកមានទំហំធំ អ្នកចាំបាច់ត្រូវចងក្រងរបាយការណ៍វាយតំលៃផលប៉ះពាល់បរិស្ថាន និងបញ្ជូនទៅក្រសួងបរិស្ថានដើម្បីពិនិត្យមើលឡើងវិញ និងអនុម័ត ។ ប្រសិនបើសហគ្រាសរបស់អ្នកមានទំហំតូច ឬមធ្យម អ្នកចាំបាច់ត្រូវចុះហត្ថលេខា លើកិច្ចសន្យាការពារបរិស្ថានជាមួយនឹងមន្ទីរបរិស្ថានខេត្ត/ក្រុង ។ | |
| 🕮 គ្រប់សហគ្រាសទាំងអស់ត្រូវតែបរិច្ចាគជំនួយទៅក្នុង មូលនិធិទាយជូទានបរិស្ថាន ដែលអធិប្បាយនៅក្នុងមាត្រា ១៩ នៃជំពូក ៨ នៃច្បាប់ស្តីអំពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។ | ✍ អ្នកគួរតែបរិច្ចាគជំនួយទៅក្នុងមូលនិធិទាយជូទានបរិស្ថាន ។ បរិមាណនៃជំនួយគឺតាមការស្ម័គ្រចិត្ត ។ | |

គោលបំណងនៃអធិការកិច្ចលើការគ្រប់គ្រងបរិស្ថានគឺដើម្បីការពារ និងកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ដើម្បីការពារសុខភាពសាធារណៈ គុណភាព បរិស្ថាន និងជីវៈចំរុះ ។ សហគ្រាសទាំងឡាយដែលមានសកម្មភាពធុរកិច្ចដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ 3A ត្រូវឆ្លងកាត់ អធិការកិច្ចបរិស្ថាន ។ អាស្រ័យទៅលើវិសាលភាពនៃការបំពុល ការរំខាន និងការបំផ្លាញធនធានធម្មជាតិ មន្ត្រីអធិការកិច្ចបរិស្ថាន នឹងចុះពិនិត្យ និងផ្តល់ព័ត៌មានលើបញ្ហាបរិស្ថានទាំងអស់ដែលកើតមាននៅក្នុងដែនដីរបស់ខ្លួន ។ អធិការកិច្ចត្រូវធ្វើឡើងជារៀងរាល់ឆ្នាំប៉ុន្តែ មន្ត្រីអធិការកិច្ចបរិស្ថានអាចធ្វើអធិការកិច្ចនៅតាមសហគ្រាសដោយមិនជូនដំណឹងជាមុន បើសិនជាមានពាក្យបណ្តឹង ឬមានការផ្តល់ព័ត៌មានផ្សេងៗ ។

**រូបទី ៥: នីតិវិធីអធិការកិច្ចលើការគ្រប់គ្រងបរិស្ថាន**




**សំគាល់:** អធិការកិច្ចដោយនាយកដ្ឋានគ្រប់គ្រងការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានខេត្ត/ក្រុង)

## តារាង ៩: ការណែនាំសំរាប់អធិការកិច្ចលើការគ្រប់គ្រងបរិស្ថាន

| ជំហាន | ការណែនាំ |
|---|---|
| ជំហានទី ១ | ▪ ដើម្បីជៀសវាងមន្ត្រីអធិការកិច្ចដែលគ្មានការអនុញ្ញាតមកត្រួតពិនិត្យ សូមពិនិត្យមើលឯកសណ្ឋាន និង សួររកអត្តសញ្ញាណប័ណ្ណរបស់មន្ត្រីអធិការកិច្ច និងលិខិតបេសកកម្ម ដែលចេញដោយក្រសួង ឬមន្ទីរបរិស្ថាន។<br>▪ អ្នកអាចសួររកហេតុផលនៃការចុះធ្វើអធិការកិច្ច |
| ជំហានទី ២ | ▪ ប្រសិនបើនេះជាអធិការកិច្ចដែលបានជូនដំណឹងជាមុន អ្នកត្រូវត្រៀមកំណត់ត្រា និងឯកសារពាក់ពន្ធ័សំរាប់ការធ្វើអធិការកិច្ច<br>▪ ត្រូវអមដំណើរមន្ត្រីអធិការកិច្ចនៅក្នុងពេលធ្វើអធិការកិច្ច ដើម្បីឆ្លើយសំនួរមន្ត្រីអធិការកិច្ចបើសិនជាមាន។<br>▪ ក្នុងករណីខ្លះ មន្ត្រីអធិការកិច្ចអាចយកសំណាកសំរាប់ការធ្វើវិភាគនៅមន្ទីរពិសោធន៏។ សហគ្រាសត្រូវបង់ថ្លៃវិភាគទាំងនោះ។ សហគ្រាសអាចសួរអំពីមូលហេតុនៃការធ្វើអធិការកិច្ច បញ្ហាបរិស្ថាន និងហានិភ័យដែលពាក់ព័ន្ធ។<br>▪ ក្នុងករណីមានបទល្មើសជាក់ស្តែង និងជះឥទ្ធិពលដល់សុខភាពសាធារណៈ មន្ត្រីអធិការកិច្ចបរិស្ថានអាចធ្វើសកម្មភាពបញ្ឈប់ការបំពុល ឬរំខានជាបន្ទាន់ |
| ជំហានទី ៣ | ▪ ប្រសិនបើមន្ត្រីអធិការកិច្ចរកឃើញករណីមិនអនុលោម សហគ្រាសអាចសុំឱ្យមន្ត្រីអធិការកិច្ចបញ្ជាក់ឱ្យបានច្បាស់អំពីបញ្ហាដែលមិនអនុលោម និងប្រាកដថាអ្នកត្រូវធ្វើអ្វីដើម្បីអនុលោម<br>▪ ប្រសិនបើមិនច្បាស់ថាត្រូវធ្វើដូចម្តេចដើម្បីដោះស្រាយបញ្ហាមិនអនុលោម សហគ្រាសអាចសុំយោបល់ពីមន្ត្រីអធិការកិច្ចបាន<br>▪ ត្រូវប្រាកដថាពេលវេលាដែលផ្តល់ដោយមន្ត្រីអធិការកិច្ច មានគ្រប់គ្រាន់សំរាប់ចាត់ចែងសកម្មភាពកែតំរូវ<br>▪ ត្រូវអានរបាយការណ៏អធិការកិច្ចដោយប្រុងប្រយ័ត្នមុននឹងចុះហត្ថលេខា<br>▪ ក្នុងករណីអ្នកមិនព្រមចុះហត្ថលេខា មន្ត្រីអធិការកិច្ចបរិស្ថានអាចអនុវត្តនិតិវិធីនេះបានតាមរយៈសាក្សី និងភស្តុតាងដែលមាន |
| ជំហានទី ៤ | ▪ ប្រសិនបើមន្ត្រីអធិការកិច្ចរកឃើញភាពមិនអនុលោម សហគ្រាសត្រូវប្រាកដថាសកម្មភាពកែតំរូវដែលបានព្រមព្រៀង ត្រូវបានធ្វើរួចរាល់តាមពេលវេលា និងត្រូវបានដោះស្រាយឱ្យបានមុនអធិការកិច្ចតាមដាន។<br>▪ សួររករបាយការណ៏អធិការកិច្ច<br>▪ ក្នុងករណីមានការយកសំណាកសំរាប់ការធ្វើវិភាគនៅមន្ទីរពិសោធន៏ សហគ្រាសអាចសួររកលទ្ធផលវិភាគនៅមន្ទីរពិសោធន៏ |
| ជំហានទី ៥ | ▪ ក្នុងករណីសហគ្រាសបានធ្វើតាមសកម្មភាពកែតម្រូវហើយនោះ មន្ទីរ ឬក្រសួងបរិស្ថាននឹងចេញលិខិតបញ្ជាក់ភាពអនុលោម |
| ជំហានទី ៦ | ▪ ក្នុងករណី សហគ្រាសមិនបានអនុវត្តតាមសកម្មភាពកែតម្រូវនោះ មន្ទីរ ឬក្រសួងបរិស្ថាននឹងចេញលិខិតរដ្ឋបាល និងវិធានការកែប្រែ និងទុកពេលឱ្យអ្នកធ្វើការកែតម្រូវ<br>▪ មន្ត្រីអធិការកិច្ចបរិស្ថានអាចតម្រូវឱ្យអ្នកចុះហត្ថលេខាលើកិច្ចសន្យាកែតម្រូវ |
| ជំហានទី ៧ | ▪ ដូចបានពន្យល់នៅរូបភាពទី៤ |
| ជំហានទី ៨ | ▪ ដូចបានពន្យល់នៅរូបភាពទី៤ |
| ជំហានទី ៩ | ▪ ដូចបានពន្យល់នៅរូបភាពទី៤ |

# អធិការកិច្ចការងារ

គោលបំណងនៃអធិការកិច្ចការងារ គឺដើម្បីធានាឱ្យសហគ្រាសទាំងឡាយគោរពតាមច្បាប់ការងារ និងបទបញ្ញត្តិជាធរមាន។ សហគ្រាសផលិតម្ហូបអាហារ និងភេសជ្ជៈទាំងអស់ ដែលប្រើកម្មករលើសពី ៨ នាក់ជាប្រចាំ គឺជាកម្មវត្ថុនៃអធិការកិច្ចការងារ។ បើសិនជាសហគ្រាសខ្នាតធំ (ប្រើប្រាស់កម្មករលើសពី ១០០ នាក់) មន្ត្រីអធិការកិច្ច មកពីនាយកដ្ឋានអធិការកិច្ចការងារនឹងមកត្រួតពិនិត្យសហគ្រាសនោះ។ ប្រសិនបើសហគ្រាសជាសហគ្រាសខ្នាតតូចនិងមធ្យម (ប្រើប្រាស់កម្មករចាប់ពី ១០០នាក់ចុះក្រោម) មន្ត្រីអធិការកិច្ចមកពី មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងត្រួតពិនិត្យសហគ្រាសនោះ។ ក្រុមអធិការកិច្ចការងារនឹងត្រួតពិនិត្យសហគ្រាសរបស់អ្នកជាប្រចាំភាពញឹកញាប់នៃការធ្វើអធិការកិច្ចអាស្រ័យលើស្ថានភាពគោរពច្បាប់និងបទបញ្ញត្តិផ្សេងៗ។ ប្រសិនបើមានពាក្យបណ្តឹង មន្ត្រីអធិការកិច្ចអាចចុះមកត្រួតពិនិត្យ សហគ្រាសរបស់អ្នកដោយមិនមានសេចក្តីជូនដំណឹងជាមុន។

### តារាង ១០: ច្បាប់ និងអនុក្រឹត្យដែលពាក់ពន្ធ័នឹងអធិការកិច្ចវិស័យការងារ

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| ច្បាប់ការងារ | | |
| 🕮 និយោជកទាំងអស់ដែលត្រូវស្ថិតនៅក្រោមច្បាប់ការងារនេះ ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅពេលបើកសហគ្រាស ឬគ្រឹះស្ថាន។ សចក្តីប្រកាសជូនដំណឹង នេះហៅថា សេចក្តីប្រកាសជូនដំណឹង បើកសហគ្រាស ឬគ្រឹះស្ថាន ដែលត្រូវសរសេរជាលាយលក្ខណ៍អក្សរនិងដាក់ជូន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មុនពេលបើកសហគ្រាស ឬគ្រឹះស្ថានជាស្ថាពរ។ | ✍ ប្រសិនបើសហគ្រាសប្រើកម្មករលើសពី ៨ នាក់ ត្រូវដាក់សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 🗎 សេចក្តីប្រកាសជូន ដំណឹងបើកសហគ្រាស (សូមមើលឧបសម្ព័ន្ធ ៤A) |

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| **ច្បាប់ការងារ** | | |
| 🕮 និយោជកដែលប្រើកម្មករតិចជាង ៨នាក់ជាប្រចាំ និងមិនប្រើម៉ាស៊ីនត្រូវធ្វើសេចក្តីប្រកាសជូនក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ៣០ថ្ងៃ បន្ទាប់ពីបើកសហគ្រាស ។ | ✍ ធ្វើសេចក្តីប្រកាសទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៣០ថ្ងៃ បន្ទាប់ពីបើកសហគ្រាស | 🗎 សេចក្តីប្រកាសជូនដំណឹងបិទសហគ្រាស (សូមមើលតារាងឧបសម្ព័ន្ធ ៤A) |
| 🕮 ចំពោះការបិទសហគ្រាស និយោជកក៏ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងជូនក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីការបិទសហគ្រាស ។ | ✍ សហគ្រាសត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងជូនក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីការបិទសហគ្រាស ។ | |
| 🕮 នៅរាល់ពេលដែលទទួលឱ្យធ្វើការ ឬបញ្ឈប់កម្មករនិយោជិតណាម្នាក់ និយោជកត្រូវតែធ្វើសេចក្តីប្រកាសជូនដំណឹងទៅ ក្រសួងទទួលបន្ទុកវិស័យការងារ ។ សេចក្តីប្រកាសជូនដំណឹង នេះត្រូវសរសេរជាលាយលក្ខណ៍អក្សរក្នុងរយៈពេល១៥ថ្ងៃ យ៉ាងយូរបំផុតបន្ទាប់ពីថ្ងៃទទួលឱ្យធ្វើការ ឬបញ្ឈប់លែងឱ្យធ្វើការ ។<br><br>សេចក្តីប្រកាសជូនដំណឹងអំពីការទទួលឱ្យធ្វើការ ឬបញ្ឈប់លែងឱ្យធ្វើការខាងលើនេះមិនអនុវត្តចំពោះ:<br>▪ ការងារម្តងម្កាលដែលមានរយៈពេលជាប់គ្នាតិចជាង ៣០ថ្ងៃ ។<br>▪ ការងារធ្វើឈប់ ធ្វើឈប់ដែលថិរវេលាពិតប្រាកដសំរាប់ការងារនេះមិនលើសពី ៣ខែ ក្នុងរយៈពេល ១២ខែ បន្តបន្ទាប់គ្នា ។ | ✍ សហគ្រាសត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងអំពី ការទទួលឱ្យបុគ្គលិកធ្វើការ ឬបញ្ឈប់លែងឱ្យធ្វើការ ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ | 🗎 លិខិតប្រកាសជូនដំណឹងអំពីការផ្លាស់ប្តូរនិយោជិត |

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| **ច្បាប់ការងារ** | | |
| 📖 ដូចមានចែងនៅក្នុងមាត្រា ១៧ នៃច្បាប់ការងារ សហគ្រាស ឬ គ្រឹះស្ថានដែលប្រើកម្មករនិយោជិក យ៉ាងតិច ៨នាក់ ជានិច្ចកាលត្រូវបង្កើត បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ។ បទបញ្ជាផ្ទៃក្នុងត្រូវរៀបចំដោយ នាយកសហគ្រាសគ្រឹះស្ថានបន្ទាប់ពី មានការពិគ្រោះយោបល់ជាមួយ តំណាងកម្មក ។ មុនដាក់ឱ្យប្រើប្រាស់ បទបញ្ជាផ្ទៃក្នុងត្រូវតែទទួលបាន ទិដ្ឋាការពីអធិការការងារជាមុន ។ ទិដ្ឋាការនេះនឹងត្រូវចេញឱ្យក្នុង រយៈពេល ៦០ថ្ងៃ ។ | ✍ ត្រូវបង្កើតបទបញ្ជាផ្ទៃក្នុង ដោយមានការពិគ្រោះយោបល់ជា មួយតំណាងកម្មករ ហើយបទបញ្ជា ផ្ទៃក្នុងនេះត្រូវអនុម័តដោយអធិការ ការងារ ។ | 🗎 ឯកសារបទបញ្ជាផ្ទៃក្នុង |
| 📖 គ្រប់គ្រឹះស្ថាន និងទីកន្លែងធ្វើការ ត្រូវរក្សាឱ្យបានស្អាត ហើយបង្ហាញ ថាមានលក្ខខណ្ឌអនាម័យ និងសុខភាព ជានិច្ច ឬជាទូទៅត្រូវឱ្យមានលក្ខខណ្ឌ ការងារដែលចាំបាច់សំរាប់សុខភាព របស់កម្មករនិយោជិក ។ គ្រប់គ្រឹះស្ថាន និងទីកន្លែងធ្វើការត្រូវ តែរៀបចំយ៉ាង ណាឱ្យ មានការធានាសុវត្ថិភាពកម្មករ និយោជិក ។ គ្រឿង ម៉ាស៊ីន គ្រឿងយន្ត បរិធាន សំរាប់បញ្ជូន ឧបករណ៍តូច ធំ និងម៉ាស៊ីន ត្រូវដាក់ និងរៀបចំក្នុងលក្ខខណ្ឌ ប្រសើរបំផុតនៃសន្តិសុខ ។ ការចាត់ ចែងការងារបច្ចេកទេស ដែលប្រើ ប្រាស់សំភារៈឧបករណ៍ តូច ធំ ម៉ាស៊ីន ឬ ផលិតផលដែល ប្រើប្រាស់រួចត្រូវ ទុកដាក់ឱ្យបានត្រឹមត្រូវ ដើម្បីធានា ដល់ សុវត្ថិភាពរបស់កម្មករនិយោជិត ។ | ✍ អ្នកត្រូវរក្សាបរិវេណរបស់អ្នកឱ្យ ស្អាត និងបង្កើតកន្លែងធ្វើការ ដើម្បី ធានាសុវត្ថិភាពកម្មករ | |

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| 🕮 សហគ្រាស និងគ្រឹះស្ថានដែលស្ថិតក្រោមមាត្រា១នៃច្បាប់នេះត្រូវតែផ្តល់ការថែទាំសុខភាពជាបឋមដល់កម្មករនិយោជិតរបស់ខ្លួន។ | ✍ ត្រូវផ្តល់ការថែទាំសុខភាពបឋមដល់កម្មកររបស់អ្នក។ | |
| 🕮 សហគ្រាស និងគ្រឹះស្ថានទាំងអស់ដែលស្ថិតក្រោមមាត្រា ២៣៨នៃច្បាប់ការងារ ហើយដែលមានកម្មករយ៉ាងតិច ៥០នាក់ ត្រូវមានគិលានដ្ឋានជាអចិន្ត្រៃយ៍នៅក្នុងបរិវេណនៃគ្រឹះស្ថានរោងជាង ឬការដ្ឋានការងារ។ គិលានដ្ឋាននេះត្រូវតែ មានសំភារៈវត្ថុរុំរបួស ថ្នាំពេទ្យគ្រប់គ្រាន់ ដើម្បីព្យាបាលកម្មករនិយោជិតក្នុងករណីមានគ្រោះថ្នាក់ ឬជំងឺដែលបណ្តាលមកពីការងារ ឬមានជំងឺក្នុងពេលកំពុងធ្វើការ។ | ✍ ប្រសិនបើសហគ្រាសរបស់មានកម្មករច្រើនជាង ៥០នាក់ អ្នកត្រូវផ្តល់គិលានដ្ឋានជាអចិន្ត្រៃយ៍នៅក្នុងបរិវេណ ផ្គត់ផ្គង់ សំភារៈ បង់សំរាប់រុំរបួស ថ្នាំពេទ្យ ឱ្យបានគ្រប់គ្រាន់ ដើម្បីផ្តល់ការថែទាំ សង្គ្រោះបន្ទាន់ដល់កម្មករក្នុងហេតុការណ៍មានគ្រោះថ្នាក់ ឬជំងឺកើតឡើងដោយសារការងារ ឬឈឺពេលកំពុងធ្វើការ។ | |
| 🕮 ក្នុងគ្រឹះស្ថានប្រភេទណាក៏ដោយ ទោះបីគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាកិច្ចកុសលឬគ្រឹះស្ថាន មានវិជ្ជាជីវៈសេរី ថេរវេលាធ្វើការសំរាប់កម្មករទាំងពីរភេទមិនឱ្យលើសពី ៨ម៉ោង ក្នុងមួយថ្ងៃ ឬ ៤៨ម៉ោង ក្នុងមួយសប្តាហ៍ទេ។ | ✍ មិនត្រូវស្នើឱ្យកម្មករធ្វើការលើស ៤៨ម៉ោង ក្នុងមួយសប្តាហ៍ទេ។ | |
| 🕮 អាយុដែលអនុញ្ញាតឱ្យធ្វើការងារមានប្រាក់ខែគឺត្រូវកំណត់ ត្រឹម១៥ឆ្នាំឡើង។<br>🕮 អាយុអប្បបរមាចំពោះមុខរបរ ឬការងារគ្រប់ប្រភេទ ដែលអាចធ្វើឱ្យខូចសុខភាព សុវត្ថិភាព ឬសីលធម៌នៃយុវវ័យគឺ ១៨ឆ្នាំ។ | ✍ អាចជួលនិយោជិតមាន អាយុ ១៥ឆ្នាំ ប្រសិនបើការងារនោះតាមធម្មជាតិរបស់វា មិនអាចមានគ្រោះថ្នាក់ដល់ សុខភាព សុវត្ថិភាព ឬសីលធម៌របស់យុវវ័យ។ បើពុំដូច្នោះទេ និយោជិកត្រូវមានអាយុ ១៨ឆ្នាំ។ | 🗎 បញ្ជីឈ្មោះនិយោជិត រួមទាំងអាយុ និងភេទរបស់ពួកគេ |

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| 🕮 ក្មេងដែលមានអាយុពី ១២ ដល់ ១៥ឆ្នាំ អាចអនុញ្ញាត ធ្វើតែការងារស្រាលៗ ក្នុងលក្ខខណ្ឌដូចតទៅ:<br>▪ ការងារមិនមានគ្រោះថ្នាក់ដល់សុខភាព ឬការអភិវឌ្ឍន៍ផ្នែករៀងកាយ និងបញ្ញារបស់គេ ។<br>▪ កម្មករនឹងមិនប៉ះពាល់ដល់ការចូលរៀននៅសាលាជាទៀងទាត់របស់គេ ការចូលរួមក្នុងកម្មវិធីតំរង់ទិសឬកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។ | ✍ សហគ្រាសត្រូវពិនិត្យមើលថាតើ ការងារអាចមានគ្រោះថ្នាក់ដល់សុខភាព ឬ ការអភិវឌ្ឍន៍ផ្នែករាងកាយនិងបញ្ញា និងប៉ះពាល់ដល់ការចូលរៀននៅសាលារៀនរបស់ក្មេងដែរឬទេ? | 🗎 សេចក្តីប្រកាសជូនដំណឹងស្តីពីបុគ្គលិក |
| **ប្រកាសលេខ ២៦៨ ស្តីពីសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន** | | |
| 🕮 នាយក ឬ ម្ចាស់សហគ្រាស ឬ គ្រឹះស្ថាន ត្រូវរក្សាសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានឱ្យបានត្រឹមត្រូវ ហើយដែលមានចុះកាលបរិច្ឆេទ និងហត្ថលេខាដោយមន្ត្រីអធិការកិច្ច ។ | ✍ សហគ្រាសត្រូវមានសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានដែលមានចុះលេខរៀង និង ហត្ថលេខាដោយមន្ត្រីអធិការកិច្ច (សូមមើលតារាងឧបសម្ព័ន្ធ ៤A) | 🗎 សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន |
| **ប្រកាសលេខ ១៤៧ ស្តីពីប័ណ្ណអនុញ្ញាតឱ្យធ្វើការងារសំរាប់និយោជិកខ្មែរ** | | |
| 🕮 ដូចដែលមាន ចែងក្នុងមាត្រា ១នៃច្បាប់ការងារ នាយក ឬម្ចាស់សហគ្រាស ឬគ្រឹះស្ថានមិនត្រូវជួលកម្មករនិយោជិតខ្មែរ ដរាបណាគេមិនមានប័ណ្ណការងារដែលមានសុពលភាព និងត្រូវសំរួលដល់កម្មករនិយោជិកដើម្បីមក និងបំពេញពាក្យសុំ ដើម្បីទទួលបានប័ណ្ណការងារ ។ | ✍ មិនត្រូវជួលនិយោជិតកម្មករខ្មែរដោយមិនមានប័ណ្ណការងារ និងត្រូវជួយពួកគេក្នុងការដាក់ពាក្យសុំ ។ | 🗎 ប័ណ្ណការងារនៃ កម្មករនិយោជិតខ្មែរ |

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| **ប្រកាសលេខ ១៦១ ស្តីពីការជួលកម្មករបរទេស** | | |
| 📖 ដូចដែលមានចែងក្នុងមាត្រា ១នៃច្បាប់ការងារ នាយក ឬម្ចាស់សហគ្រាស ឬ គ្រឹះស្ថាន គួរផ្តល់អទិភាពទៅឱ្យជនកម្ពុជានៅពេលគេជ្រើសរើសនិយោជិត ។ ក្នុងករណីដែលគេមិនអាចរកជនកម្ពុជាណាម្នាក់បានដើម្បីធ្វើកិច្ចការជាក់លាក់ណាមួយ នាយក ឬ ម្ចាស់សហគ្រាសឬគ្រឹះស្ថាន អាចជ្រើសរើសកម្មករបរទេសដែលជាអ្នកជំនាញ អ្នកបច្ចេកទេសឬជំនាញការ ដើម្បីបំពេញកន្លែងធ្វើការ ដែលកម្មករកម្ពុជាមិនអាចធ្វើបាន ។ ម្ចាស់ និងអ្នកគ្រប់គ្រងត្រូវតែដាក់លិខិតស្នើជាមុនដើម្បីសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ | ✍ ប្រសិនបើអ្នកចង់ជួលកម្មករបរទេស អ្នកត្រូវធ្វើសំណើទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។<br><br>**កំណត់សំគាល់:** ពីមុននីតិវិធីត្រូវបានបកស្រាយខាងឆ្វេង ដូចនីតិវិធី ឥឡូវនេះលិខិតប្រកាសត្រូវដាក់ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពិនិត្យ ។ | 🗎 លិខិតអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **ប្រកាសលេខ ១៦២ ស្តីពីប័ណ្ណអនុញ្ញាតឱ្យធ្វើការងារសំរាប់កម្មករបរទេស និងប័ណ្ណការងារ** | | |
| 📖 នាយក ឬម្ចាស់សហគ្រាស ឬ គ្រឹះស្ថានដែលជួលកម្មករបរទេស ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងពីកម្មករបរទេស និងកិច្ចសន្យាការងាររបស់ពួកគេ ទៅនាយកដ្ឋានវិជ្ជាជីវៈ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រសីនបើគេជួលកម្មករនៅភ្នំពេញ ។ ប្រសិនបើជួលកម្មករនៅខេត្ត-ក្រុងផ្សេង សហគ្រាសត្រូវប្រកាសជូនមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត-ក្រុង ។ | ✍ ក្នុងករណីសហគ្រាសចង់ជួលកម្មករបរទេស ជាដំបូងត្រូវធ្វើលិខិតស្នើទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសិន ។<br><br>**កំណត់សំគាល់:** ពីមុននីតិវិធីត្រូវបានបកស្រាយខាងឆ្វេង ដូចនីតិវិធី ឥឡូវនេះលិខិតប្រកាសត្រូវដាក់ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពិនិត្យ ។ | 🗎 សៀវភៅការងារ និង ប័ណ្ណការងារ របស់កម្មករបរទេស |

| អ្វីដែលបទបញ្ញត្តិបានចែង | អ្វីដែលអ្នកត្រូវធ្វើ | ឯកសារអ្វីខ្លះដែលអ្នកគួរមាន |
|---|---|---|
| **ប្រកាសលេខ ២៦៩ ស្តីពីការបង្កើតសៀវភៅបើកប្រាក់** | | |
| 📖 ដូចដែលមានចែងក្នុងមាត្រា ១នៃច្បាប់ការងារ នាយក ឬ ម្ចាស់សហគ្រាស ឬ គ្រឹះស្ថាន ត្រូវរក្សាទុកសៀវភៅបើកប្រាក់ ។<br>📖 សៀវភៅបើកប្រាក់នេះនឹងទុកជាត្រឹមត្រូវ លុះត្រាតែមានចុះលេខទំព័រ និងហត្ថលេខារបស់មន្ត្រីអធិការកិច្ចការងារគ្រប់ទំព័រ ។<br>📖 សៀវភៅទូទាត់ត្រូវតែរក្សានៅក្នុងការិយាល័យបេឡា ឬទីចាត់ការនៃសហគ្រាស គ្រឹះស្ថាន ដើម្បីងាយស្រួលត្រួតពិនិត្យ ។ | ✍ អ្នកត្រូវមាន និងរក្សាសៀវភៅបើកប្រាក់នៅក្នុងការិយាល័យ បេឡា ឬទីចាត់ការនៃសហគ្រាស សំរាប់អធិការកិច្ច ។ សៀវភៅបើកប្រាក់ត្រូវមានចុះលេខទំព័រ និងហត្ថលេខារបស់មន្ត្រីអធិការកិច្ចការងារគ្រប់ទំព័រ ។ | 🗎 សៀវភៅបើកប្រាក់ |
| **ប្រកាសលេខ ០៩ អំពីការត្រួតពិនិត្យសុខភាព និងកាយសម្បទារបស់កម្មករបរទេស និងខ្មែរនៅកម្ពុជា** | | |
| 📖 ដូចមានចែងក្នុងមាត្រា១នៃច្បាប់ការងារ ពលរដ្ឋខ្មែរ ឬបរទេសទាំងពីរភេទដែលធ្វើការនៅកម្ពុជា តំរូវឱ្យឆ្លងកាត់ការត្រួតពិនិត្យសុខភាព ។ | ✍ សហគ្រាសត្រូវឱ្យកម្មករទៅពិនិត្យសុខភាពមុនពេល ជួលគាត់ ។ | 🗎 វិញ្ញាបនប័ត្របញ្ជាក់សុខភាពរបស់កម្មករ |
| **ប្រកាសលេខ ២៨៦ ស្តីពីប្រតិភូបុគ្គលិកនៅក្នុងគ្រឹះស្ថាន និង សហគ្រាស** | | |
| 📖 រាល់គ្រឹះស្ថាន និងសហគ្រាសទាំងអស់ដែលបានចែងក្នុងមាត្រា១នៃច្បាប់ការងារ ដែលមានកម្មករយ៉ាងតិច៨នាក់ត្រូវបង្កើតប្រតិភូបុគ្គលិកនិងជំនួយការ ។ ប្រតិភូបុគ្គលិក និងជំនួយការ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយកម្មករ និងនិយោជិតសំរាប់រយៈពេល ២ឆ្នាំម្តង ។ | ✍ មានវត្តមាននៅពេលបោះឆ្នោត របាយការណ៍បោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក និងជំនួយការ ហើយផ្ញើច្បាប់ចំលងនៃរបាយការណ៍មួយច្បាប់ទៅកាន់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅជិតសហគ្រាសរបស់អ្នក ។ | 🗎 របាយការណ៍នៃការបោះឆ្នោតប្រតិភូបុគ្គលិក និងជំនួយការ ។ |

## រូបទី ៦: នីតិវិធីអធិការកិច្ចការងារ

**ជំហាន ១** ការបើកកិច្ចប្រជុំ

មន្ត្រីអធិការកិច្ច (ធ្វើការណែនាំខ្លួន និង គោល បំណង បង្ហាញលិខិតបេសកម្ម អត្តសញ្ញាណប័ណ្ណ)

**ជំហាន ២** ធ្វើអធិការកិច្ចនៅទីងកន្លែងនិង, ឬត្រួតពិនិត្យឯកសារ

*តម្រូវការសំរាប់សហគ្រាស*

- សេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស
- សេចក្ដីប្រកាសជូន ដំណឹងពីចលនាបុគ្គលិក
- សៀវភៅបើកប្រាក់
- ប្រើប្រាស់បានត្រឹមត្រូវនៃសៀវភៅបើកប្រាក់
- បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស
- ការបោះឆ្នោតប្រតិភូបុគ្គលិក
- ការផ្សព្វផ្សាយបទបញ្ជាផ្ទៃក្នុង
- បញ្ជីឈ្មោះកម្មករដោយមានអាយុ និងភេទ
- ប័ណ្ណការងារ និង សៀវភៅការងារ
- វិញ្ញាបនប័ត្រពិនិត្យសុខភាព
- ឯកសារផ្សេងទៀតពាក់ព័ន្ធនឹងសហគ្រាស

*លក្ខខណ្ឌការងារជាទូទៅ*

- ម៉ោងធ្វើការ
- ពេលសំរាកប្រចាំសប្ដាហ៍
- ការងារពេលយប់
- ពលកម្មរបស់ស្ត្រី និងកូនក្មេង
- ប្រាក់ឈ្នួល ប្រាក់បំណាច់ ប្រាក់រង្វាន់ផ្សេងៗ
- អនាម័យ និងសន្តិសុខការងារ

**ជំហាន ៣** ការបិទកិច្ចប្រជុំ

- ពិភាក្សាការរកឃើញ (ជាពិសេសភាពមិនអនុលោម) ប្រសិនបើមាន
- ឯកភាពគ្នានៅពេលវេលាសំរាប់ការកែតំរូវ ប្រសិបើមាន
- រៀបចំរបាយការណ៍អធិការកិច្ច
- ចុះហត្ថលេខាលើរបាយការណ៍អធិការកិច្ច

**ជំហាន ៤** អធិការកិច្ចតាមដាន

**សំគាល់:** អធិការកិច្ចធ្វើឡើងដោយនាយកដ្ឋានអធិការកិច្ចការងារនៃ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ឬមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។ មិនមានការបង់ថ្លៃចំណាយសំរាប់អធិការកិច្ចនេះទេ ។

**តារាង ១១: ការណែនាំសំរាប់អធិការកិច្ចការងារ**

| ដំណាក់ | ការណែនាំ |
|---|---|
| ជំហានទី ១ | ▪ ដើម្បីជៀសវាង មន្ត្រីអធិការកិច្ចដែលមិនមានការអនុញ្ញាតមកត្រួតពិនិត្យ សូមសួររកអត្តសញ្ញាណប័ណ្ណ និងលិខិតបេសកកម្មដែលចេញដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ |
| ជំហានទី ២ | ▪ ប្រសិនបើអធិការកិច្ចមានការជូនដំណឹង សហគ្រាសត្រូវរៀបចំឯកសារពាក់ពន្ធ័សំរាប់អធិការកិច្ច ។<br>▪ សហគ្រាសត្រូវអមមន្ត្រីអធិការកិច្ចក្នុងអំឡុងពេលអធិការកិច្ចនៅនឹងកន្លែង ប្រសិនជាគេរកឃើញបញ្ហាណាមួយត្រូវឱ្យអ្នកបញ្ជាក់ ។ |
| ជំហានទី ៣ | ▪ ប្រសិនបើកមន្ត្រីអធិការកិច្ចរកឃើញភាពមិនអនុលោម អ្នកត្រូវសួរមន្ត្រីអធិការកិច្ចដើម្បីបញ្ជាក់បញ្ហាភាពមិនអនុលោម និងប្រាកដថាអ្នកត្រូវធ្វើអ្វីដើម្បីអនុលោម ។<br>▪ ប្រសិនបើមិនសូវច្បាស់ថាត្រូវធ្វើដូចម្តេចដើម្បីដោះស្រាយភាពមិនអនុលោម ត្រូវសួរយោបល់ពីមន្ត្រីអធិការកិច្ច<br>▪ ត្រូវធានាថាពេលវេលាដែលផ្តល់ដោយមន្ត្រីអធិការកិច្ចមានគ្រប់គ្រាន់ដើម្បីធ្វើការកែតំរូវ<br>▪ អ្នកគ្រប់គ្រងត្រូវអានរបាយការណ៍អធិការកិច្ចដោយប្រុងប្រយ័ត្នមុនពេល ចុះហត្ថលេខា |
| ជំហានទី ៤ | ▪ ប្រសិនបើមន្ត្រីអធិការកិច្ចរកឃើញភាពមិនអនុលោម អ្នកត្រូវប្រាកដថា ពេលវេលាសំរាប់សកម្មភាពកែតំរូវ ដែលបានឯកភាពគ្នាត្រូវបានបំពេញ និងត្រូវបានដោះស្រាយបានត្រឹមត្រូវមុនពេលមានអធិការកិច្ចតាមដានធ្វើឡើង ។ |

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១A

## ចំណាត់ថ្នាក់សត្តឃាតដ្ឋាន

- សត្តឃាតដ្ឋានគោ និង ក្របី
  - ប្រភេទ ក: សត្តឃាតច្រើនជាង ៥០ ក្បាលក្នុងរយៈពេល ២៤ ម៉ោង
  - ប្រភេទ ខ: សត្តឃាតតិចជាង ៥០ ក្បាលក្នុងរយៈពេល ២៤ ម៉ោង
- សត្តឃាតដ្ឋានជ្រូក
  - ប្រភេទ ក: សត្តឃាតច្រើនជាង ១០០ ក្បាលក្នុងរយៈពេល ២៤ ម៉ោង
  - ប្រភេទ ខ: សត្តឃាតតិចជាង ១០០ ក្បាលក្នុងរយៈពេល ២៤ ម៉ោង
- សត្តឃាតដ្ឋានបក្សី
  - ប្រភេទ ក: សត្តឃាតច្រើនជាង ៥០០០ ក្បាលក្នុងរយៈពេល ២៤ ម៉ោង
  - ប្រភេទ ខ: សត្តឃាតតិចជាង ៥០០០ ក្បាលក្នុងរយៈពេល ២៤ ម៉ោង

# ឧបសម្ព័ន្ធ ១B

## បែបបទសុំលិខិតអនុញ្ញាតបង្កើតសត្តឃាតដ្ឋាន

តែមប្រ៊ី ៥០០រៀល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ........................................ភេទ............អាយុ...........ឆ្នាំ, ជនជាតិ................សញ្ជាតិ....................
មុខរបរបច្ចុប្បន្ន.................................................................អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ.....................ផ្លូវ.................
ភូមិ/មណ្ឌល.........................ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ...........................ខេត្ត/ក្រុង.........................។

**សូមគោរពជូន**

**លោកប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល**

**កម្មវត្ថុ** : សំណើសុំបង្កើតសត្តឃាតដ្ឋាន

**យោង** : -អនុក្រឹត្យលេខ ១០៨ អនក្រ.បក, ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ

-ប្រកាសលេខ......................ប្រក.កសក, ចុះថ្ងៃទី........ខែ...........ឆ្នាំ២០០.... ស្តីពី គំរូលិខិតអនុញ្ញាត ទម្រង់បែបបទសុំបង្កើតសត្តឃាតដ្ឋាន និង ការធ្វើអាជីវកម្មពិឃាតសត្វ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូនលោកប្រធាននាយកដ្ឋានមេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងបង្កើតសត្តឃាតដ្ឋាន: ☐ សត្តឃាតដ្ឋានគោ-ក្របី ☐ សត្តឃាតដ្ឋានជ្រូក ☐ សត្តឃាតដ្ឋានបក្សី ប្រភេទ " ក " ឈ្មោះសត្តឃាតដ្ឋាន...............................................ដែលមានទីតាំងស្ថិតនៅ: ផ្លូវ..........................
ភូមិ/មណ្ឌល......................ឃុំ/សង្កាត់..........................ស្រុក/ខណ្ឌ.........................ខេត្ត/ក្រុង...........................។

សូមជូនភ្ជាប់មកជាមួយនូវ:

| | |
|---|---|
| -ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤x៦ ដោយមានបញ្ជាក់ទទួលស្គាល់ពីមេឃុំ/ចៅសង្កាត់ | ចំនួន ០២ ច្បាប់ |
| -អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនថតចម្លងរបស់អ្នកស្នើសុំ | ចំនួន ០២ ច្បាប់ |
| -កិច្ចសន្យានៃការបង្កើតសត្តឃាតដ្ឋាន | ចំនួន ០២ ច្បាប់ |
| -លិខិតបញ្ជាក់លើទីតាំងសម្រាប់សាងសង់សត្តឃាតដ្ឋាន ដែលមានចុះទិដ្ឋាការពីអាជ្ញាធរខេត្ត ក្រុងសាមី | ចំនួន ០២ ច្បាប់ |
| -គំនូសប្លង់បច្ចេកទេសនៃសត្តឃាតដ្ឋាន | ចំនួន ០២ ច្បាប់ |

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោកប្រធាននាយកដ្ឋានមេត្តាពិនិត្យ និង សម្រេចដោយអនុគ្រោះ។

ធ្វើនៅ.........................ថ្ងៃទី...........ខែ...........ឆ្នាំ២០០

ហត្ថលេខា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| |
|---|
| រូបថត<br>៤x៦ |

# ប្រវត្តិរូបសង្ខេប

នាមត្រកូល និង នាមខ្លួន :.....................................................អក្សរឡាតាំង...........................................................

ភេទ.................ជនជាតិ.........................សញ្ជាតិ........................ថ្ងៃខែឆ្នាំកំណើត.................................................

ទីកន្លែងកំណើត :.........................................................................................................................................

អត្តសញ្ញាណប័ណ្ណលេខ/លិខិតឆ្លងដែនលេខ ( ថតចម្លង) ............................................................................

អាសយដ្ឋានស្នាក់នៅបច្ចុប្បន្នៈ ផ្ទះលេខ ............................ ផ្លូវ........................ ភូមិ/មណ្ឌល...................................

ឃុំ/សង្កាត់......................................ស្រុក/ខណ្ឌ..............................................ខេត្ត/ក្រុង....... ............................

ទូរស័ព្ទលេខៈ..............................................................................................................................

កម្រិតវប្បធម៌ :..........................................................................................................................................

បច្ចេកទេសជំនាញ :.....................................................................................................................................

មុខរបរបច្ចុប្បន្ន :.........................................................................................................................................

ឈ្មោះប្រពន្ធ ឬ ប្ដី :..................................................ថ្ងៃខែឆ្នាំកំណើត.....................................................

មុខរបរបច្ចុប្បន្ន :.........................................................................................................................................

ចំនួនកូន :......................នាក់ ភេទៈ ស្រី.................នាក់ ប្រុស.....................នាក់ ។

ធ្វើនៅ.........................ថ្ងៃទី..........ខែ.............ឆ្នាំ២០០..

**ស្នាមមេដៃស្ដាំ**

លេខៈ..................

បានឃើញ និង បញ្ជាក់ថាៈ

ឈ្មោះ.......................................នេះពិតជា

.........................................................និង

ពិតជាកំពុងស្នាក់នៅបច្ចុប្បន្ន ផ្ទះលេខ..............

ផ្លូវ................ភូមិ/មណ្ឌល...........................

ខេត្ត/ក្រុង..............................នេះប្រាកដមែន។

ធ្វើនៅ.........ថ្ងៃទី......ខែ..........ឆ្នាំ ២០០......

ហត្ថលេខា និង ត្រា

**មេឃុំ/ចៅសង្កាត់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា

# ស្តីពី

# ការសុំបង្កើតសត្តឃាតដ្ឋាន

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.........................................ភេទ............អាយុ...........ឆ្នាំ, ជនជាតិ................សញ្ជាតិ....................
មុខរបរបច្ចុប្បន្ន.............................................................. អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ.....................ផ្លូវ..................
ភូមិ/មណ្ឌល.........................ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ...........................ខេត្ត/ក្រុង...........................
ដែលសុំបង្កើតសត្តឃាតដ្ឋាន: ☐ សត្តឃាតដ្ឋានគោ-ក្របី ☐ សត្តឃាតដ្ឋានជ្រូក ☐ សត្តឃាតដ្ឋានបក្សី
ប្រភេទ: ☐"ក" ☐"ខ" ឈ្មោះសត្តឃាតដ្ឋាន.................................................ដែលមានទីតាំងស្ថិតនៅ: ផ្លូវ.....................
ភូមិ/មណ្ឌល.................................. ឃុំ/សង្កាត់....................................... ស្រុក/ខណ្ឌ.........................................
ខេត្ត/ក្រុង...................................................។

សូមសន្យាចំពោះ ☐នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ☐មន្ទីរកសិកម្ម ថាខ្ញុំបាទ/នាងខ្ញុំយល់ព្រម:

- គោរព និង អនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ បទប្បញ្ញត្តិ បទដ្ឋានបច្ចេកទេស និង សេចក្តីណែនាំផ្សេងៗរបស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ដែលពាក់ព័ន្ធការបង្កើតសត្តឃាតដ្ឋាន
- សហការ និង បង្កលក្ខណៈងាយស្រួលជានិច្ច ដល់គ្រប់សកម្មភាពការងារត្រួតពិនិត្យ របស់មន្ត្រីមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង មន្ត្រីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល
- អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានបសុពេទ្យ និង អនាម័យល្អ ធានាមិនបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និង ការរស់នៅរបស់ប្រជាពលរដ្ឋ ជុំវិញសត្តឃាតដ្ឋាន
- សរសេរជាលាយលក្ខអក្សរ សុំការអនុញ្ញាតជាមុន ក្នុងករណីមានការលក់ ឬ ជួលសត្តឃាតដ្ឋានទៅឱ្យអ្នកដទៃ
- មិនប្រើប្រាស់សត្តឃាតដ្ឋាន ជាមូលដ្ឋាននៃសកម្មភាពផ្សេងៗ

ក្នុងករណីខ្ញុំបាទ/នាងខ្ញុំមិនបានគោរព និង អនុវត្តតាមខ្លឹមសារដែលបានសន្យាខាងលើទេនោះ ខ្ញុំបាទ/នាងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន។

ធ្វើនៅ...................ថ្ងៃទី..........ខែ...............ឆ្នាំ២០០...

ហត្ថលេខា

តែមប្រី ៥០០រៀល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ........................................ភេទ............អាយុ...........ឆ្នាំ, ជនជាតិ................សញ្ជាតិ.....................
មុខរបរបច្ចុប្បន្ន.................................................................អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ.....................ផ្លូវ.................
ភូមិ/មណ្ឌល.........................ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ............................ខេត្ត/ក្រុង..........................។

**សូមគោរពជូន**

**លោកប្រធានមន្ទីរកសិកម្មខេត្ត..............**

**កម្មវត្ថុ** : សំណើសុំបង្កើតសត្តឃាតដ្ឋាន

**តាមរយៈ** លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាល

**យោង** : -អនុក្រឹត្យលេខ ១០៨ អនក្រ.បក, ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ

-ប្រកាសលេខ........................ប្រក.កសក, ចុះថ្ងៃទី........ខែ..........ឆ្នាំ២០០.... ស្តីពី គំរូលិខិតអនុញ្ញាត ទម្រង់បែបបទសុំបង្កើតសត្តឃាតដ្ឋាន និង ការធ្វើអាជីវកម្មពិឃាតសត្វ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូនលោកប្រធានមន្ទីរកសិកម្មខេត្ត.................មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងបង្កើតសត្តឃាតដ្ឋានៈ ☐ សត្តឃាតដ្ឋានគោ-ក្របី ☐ សត្តឃាតដ្ឋានជ្រូក ☐ សត្តឃាតដ្ឋានបក្សី ប្រភេទ " ខ " ឈ្មោះសត្តឃាតដ្ឋាន..............................ដែលមានទីតាំងស្ថិតនៅៈ ផ្លូវ......................
ភូមិ/មណ្ឌល........................ឃុំ/សង្កាត់..........................ស្រុក/ខណ្ឌ................................ខេត្ត/ក្រុង......................។

សូមជូនភ្ជាប់មកជាមួយនូវៈ

-ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤x៦ ដោយមានបញ្ជាក់ទទួលស្គាល់ពីមេឃុំ/ចៅសង្កាត់ ចំនួន ០២ ច្បាប់
-អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនថតចម្លងរបស់អ្នកស្នើសុំ ចំនួន ០២ ច្បាប់
-កិច្ចសន្យានៃការបង្កើតសត្តឃាតដ្ឋាន ចំនួន ០២ ច្បាប់
-លិខិតបញ្ជាក់លើទីតាំងសម្រាប់សាងសង់សត្តឃាតដ្ឋាន ដែលមានចុះទិដ្ឋាការពីអាជ្ញាធរខេត្ត ក្រុងសាមី ចំនួន ០២ ច្បាប់
-គំនូសប្លង់បច្ចេកទេសនៃសត្តឃាតដ្ឋាន ចំនួន ០២ ច្បាប់

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមន្ទីរមេត្តាពិនិត្យ និង សម្រេចដោយអនុគ្រោះ។

ធ្វើនៅ........................ថ្ងៃទី............ខែ............ឆ្នាំ២០០

ហត្ថលេខា

# ឧបសម្ព័ន្ធ ១៤

## បែបបទសុំលិខិតអនុញ្ញាតអាជីវកម្មពិឃាតសត្វ

តែមប្រើ ៥០០រៀល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................................ភេទ...........អាយុ...........ឆ្នាំ, ជនជាតិ...............សញ្ជាតិ...................
មុខរបរបច្ចុប្បន្ន...............................................................អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ....................ផ្លូវ.................
ភូមិ/មណ្ឌល.......................ឃុំ/សង្កាត់.......................ស្រុក/ខណ្ឌ..........................ខេត្ត/ក្រុង.........................។

**សូមគោរពជូន**

**លោកប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល**

**កម្មវត្ថុ** : សំណើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ

**យោង** : -អនុក្រឹត្យលេខ ១០៨ អនក្រ.បក, ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ

-ប្រកាសលេខ......................ប្រក.កសក, ចុះថ្ងៃទី........ខែ............ឆ្នាំ២០០.... ស្តីពី គំរូលិខិតអនុញ្ញាត ទម្រង់បែបបទសុំបង្កើតសត្តឃាតដ្ឋាន និង ការធ្វើអាជីវកម្មពិឃាតសត្វ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូនលោកប្រធាននាយកដ្ឋានមេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងធ្វើអាជីវកម្មពិឃាតសត្វ: ☐ គោ-ក្របី ☐ ជ្រូក ☐ បក្សី ចំនួន.................ក្បាល/ឆ្នាំក្នុងសត្តឃាតដ្ឋាន ប្រភេទ " ក " ឈ្មោះសត្តឃាតដ្ឋាន...............................ដែលមានទីតាំងស្ថិតនៅ: ផ្លូវ......................
ភូមិ/មណ្ឌល..................ឃុំ/សង្កាត់..........................ស្រុក/ខណ្ឌ..........................ខេត្ត/ក្រុង..... ......................។

សូមជូនភ្ជាប់មកជាមួយនូវ:

- -ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤x៦ ដោយមានបញ្ជាក់ទទួលស្គាល់ពីមេឃុំ/ចៅសង្កាត់ ចំនួន ០២ ច្បាប់
- -អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនថតចម្លងរបស់អ្នកស្នើសុំ ចំនួន ០២ ច្បាប់
- -កិច្ចសន្យានៃការធ្វើអាជីវកម្មពិឃាតសត្វ ចំនួន ០២ ច្បាប់

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោកប្រធាននាយកដ្ឋានមេត្តាពិនិត្យ និង សម្រេចដោយអនុគ្រោះ ។

ធ្វើនៅ.......................ថ្ងៃទី...........ខែ............ឆ្នាំ២០០

ហត្ថលេខា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា
# ស្តីពី
# ការសុំធ្វើអាជីវកម្មពិឃាតសត្វ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................................ភេទ............អាយុ...........ឆ្នាំ, ជនជាតិ................សញ្ជាតិ.....................
មុខរបរបច្ចុប្បន្ន.............................................................. អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ.....................ផ្លូវ..................
ភូមិ/មណ្ឌល.........................ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ............................ខេត្ត/ក្រុង..........................
ដែលត្រូវធ្វើអាជីវកម្មពិឃាតសត្វនៅក្នុងសត្តឃាតដ្ឋាន:☐សត្តឃាតដ្ឋានគោ ក្របី ☐សត្តឃាតដ្ឋានជ្រូក ☐សត្តឃាតដ្ឋានបក្សី ដែលមានទីតាំងស្ថិតនៅ:ផ្ទះលេខ.....................ផ្លូវ.................ភូមិ/មណ្ឌល..........................ឃុំ/សង្កាត់......................... ស្រុក/ខណ្ឌ............................ខេត្ត/ក្រុង..........................។

សូមសន្យាចំពោះ ☐ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ☐ ការិយាល័យផលិតកម្ម និង បសុព្យាបាលថា ខ្ញុំបាទ/នាងខ្ញុំយល់ព្រម:

- គោរព និង អនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ បទប្បញ្ញត្តិ និង សេចក្តីណែនាំផ្សេងៗរបស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល និង អង្គភាពដែលពាក់ព័ន្ធក្រោមឱវាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- មិនធ្វើអាជីវកម្មពិឃាតសត្វ ដែលមិនស្របតាមលក្ខខណ្ឌបច្ចេកទេស និង នាំឱ្យប៉ះពាល់ដល់មនុស្ស និង សត្វ
- មិនធ្វើអាជីវកម្មពិឃាតសត្វ ដោយគ្មានការអនុញ្ញាត
- ធ្វើអាជីវកម្មពិឃាតសត្វណា ដែលមានសុខភាពល្អ និង មានលិខិតបញ្ជាក់សុខភាពត្រឹមត្រូវពីសមត្ថកិច្ចបសុពេទ្យប្រចាំការសត្តឃាតដ្ឋាន
- បង់កម្រៃសេវាកម្មត្រួតពិនិត្យអនាម័យសាច់ និង ផលិតផលសត្វគ្រប់ចំនួនជាប្រចាំ
- សហការ និង បង្កលក្ខណៈងាយស្រួលជានិច្ច ដល់គ្រប់សកម្មភាពការងារត្រួតពិនិត្យរបស់មន្ត្រីផលិតកម្ម និង បសុព្យាបាល មានសមត្ថកិច្ចនៃមន្ទីរកសិកម្មខេត្ត ក្រុងសាមី និងមន្ត្រីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ក្នុងករណីខ្ញុំបាទ/នាងខ្ញុំមិនបានគោរព និង អនុវត្តតាមខ្លឹមសារដែលបានសន្យាខាងលើទេនោះ ខ្ញុំបាទ/នាងខ្ញុំសូមទទួលខុសត្រូវទាំងស្រុង ចំពោះមុខច្បាប់ជាធរមាន។

ធ្វើនៅ...................ថ្ងៃទី..........ខែ...............ឆ្នាំ២០០...

ហត្ថលេខា

តែមប្រើ ៥០០រៀល

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................................ភេទ............អាយុ...........ឆ្នាំ, ជនជាតិ................សញ្ជាតិ...................
មុខរបរបច្ចុប្បន្ន...................................................................អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ.....................ផ្លូវ..................
ភូមិ/មណ្ឌល.........................ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ...........................ខេត្ត/ក្រុង.........................។

## សូមគោរពជូន
## លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាល

**កម្មវត្ថុ :** សំណើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ

**យោង :** -អនុក្រឹត្យលេខ ១០៨ អនក្រ.បក, ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ

-ប្រកាសលេខ......................ប្រក.កសក, ចុះថ្ងៃទី........ខែ............ឆ្នាំ២០០.... ស្តីពី គំរូលិខិតអនុញ្ញាត ទម្រង់បែបបទសុំបង្កើតសត្តឃាតដ្ឋាន និង ការធ្វើអាជីវកម្មពិឃាតសត្វ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូនលោកប្រធានការិយាល័យមេត្តាជ្រាបថាខ្ញុំបាទ/នាងខ្ញុំមានបំណងធ្វើអាជីវកម្មពិឃាតសត្វ: ☐ គោ-ក្របី ☐ ជ្រូក ☐ បក្សី ចំនួន. ......................ក្បាល/ឆ្នាំ ក្នុងសត្តឃាតដ្ឋាន ប្រភេទ " ខ " ឈ្មោះសត្តឃាតដ្ឋាន..................................ដែលមានទីតាំងស្ថិតនៅ: ផ្លូវ..................
ភូមិ/មណ្ឌល...........................ឃុំ/សង្កាត់...........................ស្រុក/ខណ្ឌ..........................ខេត្ត/ក្រុង......................។

សូមជូនភ្ជាប់មកជាមួយនូវ:

-ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤x៦ ដោយមានបញ្ជាក់ទទួលស្គាល់ពីមេឃុំ/ចៅសង្កាត់ ចំនួន ០២ ច្បាប់
-អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនថតចម្លងរបស់អ្នកស្នើសុំ ចំនួន ០២ ច្បាប់
-កិច្ចសន្យានៃការធ្វើអាជីវកម្មពិឃាតសត្វ ចំនួន ០២ ច្បាប់

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោកប្រធានការិយាល័យមេត្តាពិនិត្យ និង សម្រេចដោយអនុគ្រោះ។

ធ្វើនៅ........................ថ្ងៃទី............ខែ............ឆ្នាំ២០០

ហត្ថលេខា

# ឧបសម្ព័ន្ធ ១D

## លិខិតអនុញ្ញាតបង្កើតសត្តឃាតដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបថត

៤x៦

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល**

លេខ :........................ផប. សឃដ

**លិខិតអនុញ្ញាត**

**បង្កើតសត្តឃាតដ្ឋាន**

- យោងអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យ អនាម័យសត្វ សាច់ និង ផលិតផលសត្វ
- យោងលិខិតឯកភាពជាគោលការណ៍លេខ........................................ចុះថ្ងៃទី ................ខែ..................ឆ្នាំ ២០០........... របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- យោងលិខិតស្នើសុំបង្កើតសត្តឃាតដ្ឋានរបស់ ....................................................................................ចុះថ្ងៃទី.................ខែ..................ឆ្នាំ ២០០......... ។

បានអនុញ្ញាតឱ្យលោក/លោកស្រី..................................................ភេទ.................អាយុ..............ឆ្នាំ ជនជាតិ..................សញ្ជាតិ.....................មុខរបរបច្ចុប្បន្ន ...............................
អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ ..............ផ្លូវ................ភូមិ...........................ឃុំ/សង្កាត់................................ស្រុក/ខណ្ឌ......................................... ខេត្ត/ក្រុង.......................................
កាន់អត្តសញ្ញាណប័ណ្ណលេខ.................................ចេញដោយ.........................................................................................................................................................
បង្កើតសត្តឃាតដ្ឋាន.................................... .......ប្រភេទ"ក"ឈ្មោះសត្តឃាតដ្ឋាន.........................................................................................មានទីតាំងស្ថិតនៅ: ផ្លូវ.......................
ភូមិ/មណ្ឌល.................................... ឃុំ/សង្កាត់..............................................ស្រុក/ខណ្ឌ...........................................ខេត្ត/ក្រុង.............................................. ។

លិខិតអនុញ្ញាតបង្កើតសត្តឃាតដ្ឋាននេះ មានសុពលភាពរយៈពេល ៥ឆ្នាំ( ប្រាំឆ្នាំ) ចាប់ពីថ្ងៃទី...........ខែ............ឆ្នាំ ២០០.......រហូតដល់ ថ្ងៃទី...........ខែ.............ឆ្នាំ ២០០........ ។
សាមីជនដែលទទួលបានលិខិតអនុញ្ញាតនេះ ត្រូវគោរព និង អនុវត្តឱ្យបានត្រឹមត្រូវ ស្របតាមកិច្ចសន្យា បទដ្ឋានបច្ចេកទេស បទបញ្ជា និង លិខិតបទដ្ឋានច្បាប់ជាធរមាន។

រាជធានីភ្នំពេញ ថ្ងៃទី ............. ខែ ........... ឆ្នាំ ២០០.............

**ប្រធាននាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល**

---

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបថត

៤x៦

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**មន្ទីរកសិកម្មខេត្ត/ក្រុង.....................**

លេខ :.........................................មក.សឃដ

**លិខិតអនុញ្ញាត**

**បង្កើតសត្តឃាតដ្ឋាន**

- យោងអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រង សត្តឃាតដ្ឋាន ការត្រួតពិនិត្យ អនាម័យសត្វ សាច់ និង ផលិតផលសត្វ
- យោងលិខិតស្នើសុំបង្កើតសត្តឃាតដ្ឋានលេខ................ .................ចុះថ្ងៃទី............ ......ខែ..............ឆ្នាំ ២០០....... .........របស់ការិយាល័យផលិតកម្ម និង បសុព្យាបាល
- យោងលិខិតឯកភាពជាគោលការណ៍លេខ:...........................ផប.ចុះថ្ងៃទី...... .........ខែ............ឆ្នាំ ២០០........ ..របស់នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល
- យោងលិខិតស្នើសុំបង្កើតសត្តឃាតដ្ឋានរបស់ ................................................... ..........ចុះថ្ងៃទី....... ......ខែ...... .....ឆ្នាំ ២០០......... ។

បានអនុញ្ញាតឱ្យលោក/លោកស្រី.............................................ភេទ....................អាយុ.............ឆ្នាំ ជនជាតិ..................សញ្ជាតិ.....................មុខរបរបច្ចុប្បន្ន ........................................
អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ .................ផ្លូវ................ភូមិ..............................ឃុំ/សង្កាត់...................................ស្រុក/ខណ្ឌ.............................ខេត្ត/ក្រុង.........................................
កាន់អត្តសញ្ញាណប័ណ្ណលេខ......................ចេញដោយ..............................................................................................................................................................
បង្កើតសត្តឃាតដ្ឋាន........................... ............................... ប្រភេទ"ខ" ឈ្មោះសត្តឃាតដ្ឋាន................................................................................... មានទីតាំងស្ថិតនៅ:ផ្លូវ...................
ភូមិ/មណ្ឌល............................ .........ឃុំ/សង្កាត់...... .............................ស្រុក/ខណ្ឌ....................................................ខេត្ត/ក្រុង............................................ ។

លិខិតអនុញ្ញាតឱ្យបង្កើតសត្តឃាតដ្ឋាននេះ មានសុពលភាពរយៈពេល ៥ ឆ្នាំ ( ប្រាំឆ្នាំ) ចាប់ពីថ្ងៃទី........ខែ............ឆ្នាំ ២០០......រហូតដល់ ថ្ងៃទី............ខែ.........ឆ្នាំ ២០០........ ។
សាមីជនដែលទទួលបានលិខិតអនុញ្ញាតនេះ ត្រូវគោរព និង អនុវត្តឱ្យបានត្រឹមត្រូវ ស្របតាមកិច្ចសន្យា បទដ្ឋានបច្ចេកទេស បទបញ្ជា និង លិខិតបទដ្ឋានច្បាប់ជាធរមាន។

...................... ថ្ងៃទី ............. ខែ ........... ឆ្នាំ ២០០.........

**ប្រធានមន្ទីរ**

# ឧបសម្ព័ន្ធ ១E

## លិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបថត
៤x៦

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល**

លេខ :..........................ផប. អពស

**លិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ**

- យោងអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រង សត្តឃាតដ្ឋាន ការត្រួតពិនិត្យ អនាម័យសត្វ សាច់ និង ផលិតផលសត្វ
- យោងលិខិតស្នើសុំធ្វើអាជីវកម្មរបស់ ..........................................ចុះថ្ងៃទី.......................ខែ...............................ឆ្នាំ ២០០.. ។

បានអនុញ្ញាតឱ្យលោក/លោកស្រី ..........................................ភេទ........... អាយុ................ឆ្នាំ ជនជាតិ.................សញ្ជាតិ..............មុខរបរបច្ចុប្បន្ន ..............................
អាសយដ្ឋានមុខរបរបច្ចុប្បន្នផ្ទះលេខ.....................ផ្លូវ..............ភូមិ/មណ្ឌល...........................ឃុំ/សង្កាត់........................ ស្រុក/ខណ្ឌ.......................ខេត្ត/ក្រុង............................
កាន់អត្តសញ្ញាណប័ណ្ណលេខ....................................ចេញដោយ..........................................................................
ធ្វើអាជីវកម្មពិឃាតសត្វ..............................ចំនួន...................ក្បាល/ឆ្នាំ ក្នុងសត្តឃាតដ្ឋានប្រភេទ "ក" ឈ្មោះសត្តឃាតដ្ឋាន............................................ ..........................
ស្ថិតនៅ: ភូមិ/មណ្ឌល......................................ឃុំ/សង្កាត់...........................................ស្រុក/ខណ្ឌ ..........................................ខេត្ត/ក្រុង ..............................................។

លិខិតអនុញ្ញាតនេះ មានសុពលភាព រយៈពេល០១ឆ្នាំ ( មួយឆ្នាំ) ចាប់ពីថ្ងៃទី...................ខែ..................ឆ្នាំ ២០០.............រហូតដល់ ថ្ងៃទី............ខែ..............ឆ្នាំ ២០០...... ។
សាមីជនដែលទទួលបានការអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ ត្រូវគោរព និង អនុវត្តឱ្យបានត្រឹមត្រូវ តាមខ្លឹមសារដូចមានចែងក្នុងកិច្ចសន្យាធ្វើអាជីវកម្ម និង លិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធជាធរមាន ដើម្បីដំណើរការអាជីវកម្មឱ្យបានល្អប្រសើរ ។

រាជធានីភ្នំពេញ .ថ្ងៃទី .......... ខែ ............ ឆ្នាំ ២០០...........

**ប្រធាននាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល**

---

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបថត
៤x៦

**មន្ទីរកសិកម្ម ខេត្ត/ក្រុង.....................**

**ការិយាល័យ ផលិតកម្ម និង បសុព្យាបាល**

លេខ :.........................កផប.អពស

**លិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ**

-យោងអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រង សត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ
-យោងលិខិតស្នើសុំធ្វើអាជីវកម្ម របស់..........................................ចុះថ្ងៃទី.....................ខែ............... .ឆ្នាំ ២០០......... ។

បានអនុញ្ញាតឱ្យលោក/លោកស្រី..........................................ភេទ........... អាយុ...............ឆ្នាំ ជនជាតិ.................សញ្ជាតិ............. មុខរបរបច្ចុប្បន្ន..............................
អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ ...................ផ្លូវ..................ភូមិ/មណ្ឌល.........................ឃុំ/សង្កាត់..............................ស្រុក/ខណ្ឌ..............................ខេត្ត/ក្រុង..............................
កាន់អត្តសញ្ញាណប័ណ្ណ លេខ.................................................ចេញដោយ..........................................................................
ធ្វើអាជីវកម្មពិឃាតសត្វ..............................ចំនួន..................ក្បាល/ឆ្នាំ ក្នុងសត្តឃាតដ្ឋានប្រភេទ " ខ " ឈ្មោះសត្តឃាតដ្ឋាន..........................................
ស្ថិតនៅ: ភូមិ/មណ្ឌល.................................ឃុំ/សង្កាត់.....................................ស្រុក/ខណ្ឌ.............................................ខេត្ត/ក្រុង.............................................. ។

លិខិតអនុញ្ញាតនេះ មានសុពលភាព រយៈពេល ០១ ឆ្នាំ ( មួយឆ្នាំ) ចាប់ពីថ្ងៃទី.................ខែ.................ឆ្នាំ ២០០.......រហូតដល់ ថ្ងៃទី...............ខែ.............ឆ្នាំ ២០០................ ។
សាមីជនដែលទទួលបានការអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ ត្រូវគោរព និង អនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារដូចមានចែងក្នុងកិច្ចសន្យាធ្វើអាជីវកម្ម និង តាមលិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធជាធរមាន ដើម្បីដំណើរការអាជីវកម្មឱ្យបានល្អប្រសើរ ។

រាជធានីភ្នំពេញ .ថ្ងៃទី .......... ខែ ............ ឆ្នាំ ២០០...........

**ប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាល**

បានឃើញ និង ឯកភាព
...............ថ្ងៃទី.......... ខែ.............ឆ្នាំ ២០០...
**ប្រធានមន្ទីរកសិកម្ម**

# ឧបសម្ព័ន្ធ ១F

## ប្រកាសស្តីពីទីតាំង និង បទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់សត្តឃាតដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ........................ប្រក.កសក

ប្រកាស

ស្តីពី

ទីតាំង និង បទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់សត្តឃាតដ្ឋាន

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក. ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋាន ផែនការ និង ស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និង ឯកសារកសិកម្ម ចំណុះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក. ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យ សត្វ និង ផលិតផលមានដើមកំណើតពីសត្វ

- បានឃើញអនុក្រឹត្យលេខ ១០៨ អនក្រ.បក. ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ

- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**សម្រេច**

**ប្រការ ១ :** ប្រកាសនេះកំណត់អំពីទីតាំង និង បទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់សត្តឃាតដ្ឋាន ដើម្បីធានាបាននូវការអនុវត្តវិធានបសុពេទ្យ អនាម័យ សុវត្ថិភាពសាច់ និង ផលិតផលសត្វ ជាប្រយោជន៍ការពារសុខភាពសាធារណៈ និង បរិស្ថាន ។

**ប្រការ ២ :** ទីតាំងសម្រាប់សាងសង់សត្តឃាតដ្ឋាននៃប្រភេទសត្វនីមួយៗ ត្រូវកំណត់លក្ខខណ្ឌដូចខាងក្រោម ÷

-ត្រូវស្ថិតនៅលើទីតាំងមួយសមស្រប ឆ្ងាយពីទីប្រជុំជន ឬ កន្លែងប្រមូលផ្តុំលំនៅដ្ឋានប្រជាជន សាលារៀន មន្ទីរពេទ្យ វត្តអារាម ទីសាធារណៈ បឹង ស្ទឹង ទន្លេ ឬ ប្រភពទឹកនានា ដែលមនុស្ស និង សត្វប្រើប្រាស់ជាប្រក្រតី

-ត្រូវស្ថិតនៅក្នុងទីតាំងណា ដែលពុំដែលទទួលរងនូវទឹកជំនន់គ្រប់រដូវកាល

-ត្រូវមានផ្ទៃដី ទំហំយ៉ាងតិចស្មើនិង ៣ដង (បីដង) នៃអគារសត្តឃាតដ្ឋាន

-ត្រូវមានប្រព័ន្ធគមនាគមន៍ល្អគ្រប់រដូវកាល ងាយស្រួលក្នុងការបម្រើសកម្មភាពដឹកជញ្ជូនចេញ ចូលសត្វ

សាច់ និង ផលិតផលសត្វ

-ត្រូវមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត សម្រាប់ប្រើប្រាស់ឱ្យបានគ្រប់គ្រាន់

-ត្រូវមានប្រព័ន្ធអគ្គិសនី សម្រាប់ប្រើប្រាស់គ្រប់គ្រាន់ និង តាមលក្ខណៈបច្ចេកទេស នៅពេលកំពុងដំណើរការក្នុងសត្តឃាតដ្ឋាន។

**ប្រការ ៣ :** បរិវេណសត្តឃាតដ្ឋានត្រូវរៀបចំកន្លែងសំខាន់ៗដូចខាងក្រោម ÷

ក.ត្រូវធ្វើរបងអំពីស៊ីម៉ង់ព័ទ្ធជុំវិញបរិវេណសត្តឃាតដ្ឋានកំពស់យ៉ាងតិច ០៣(បី)ម៉ែត្រ និង ត្រូវមានប្រព័ន្ធលូបង្ហូរទឹកកខ្វក់ កាកសំណល់ចូលក្នុងឡជីវឧស្ម័ន ឬ អាងស្តុកធ្វើប្រព្រឹត្តិកម្ម។

ខ. កន្លែងសម្រាប់មន្ត្រីបសុពេទ្យមានសមត្ថកិច្ច : បន្ទប់រដ្ឋបាល បន្ទប់យាម និង បន្ទប់ពិសោធន៍។

គ. កន្លែងសម្រាប់ម្ចាស់សត្តឃាតដ្ឋាន : បន្ទប់រដ្ឋបាល និង បន្ទប់សម្រាក។

ឃ. កន្លែងសម្រាប់កម្មករស្នាក់នៅ។

ង. កន្លែងបង្ខាំងសត្វ: សម្រាប់ដាក់សត្វសម្រាកដើម្បីពិនិត្យសុខភាពមុនពិឃាត និង សម្រាប់ដាក់សត្វឈឺ ឬ សត្វដែលសង្ស័យថាមានជំងឺ។

ច. កន្លែងសម្រាប់ជីវសុវត្ថិភាព : បន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់មុនចូលកន្លែងធ្វើការ បន្ទប់លាងសម្អាតដៃជើង មុន និង ក្រោយចេញ-ចូលកន្លែងធ្វើការ និង បន្ទប់ឆ្លងកាត់ការសម្លាប់មេរោគមុនចូលធ្វើការ។

ឆ. អគារសម្រាប់ពិឃាតសត្វ : ត្រូវរៀបចំជាផ្នែកដូចខាងក្រោម ÷

១. ផ្នែកពិឃាត

- កន្លែងបាញ់ទឹកសម្អាតសត្វ
- កន្លែងធ្វើឱ្យសត្វសន្លប់
- កន្លែងចាក់ក បង្ហូរឈាម
- កន្លែងស្រុសទឹកក្តៅ កោសរោម ដុតរោម និងពន្លាត់ស្បែក (សម្រាប់គោ ក្របី)
- កន្លែងវះពោះបារយកគ្រឿងក្នុងចេញ
- កន្លែងកាត់បំបែក បង់លេខ ឬកឹបលេខ នៅលើផ្ទាំងសាច់ និង ផលិតផលសត្វ នីមួយៗ ជៀសវាងការច្រឡំគ្នា
- កន្លែងបាញ់ទឹកលាងសម្អាតផ្ទាំងសាច់ និង ផលិតផលសត្វ។

នៅក្នុងផ្នែកនេះបន្ទាប់ពីការពិឃាតរួច សត្វត្រូវព្យួរជើងឡើងលើ ទំលាក់ក្បាលចុះមកក្រោមឱ្យផុតពីផ្ទៃក្រាល និងត្រូវរត់តាមខ្សែរ៉ៃកពីកន្លែងមួយ ទៅកន្លែងមួយទៀត។

២. ផ្នែកត្រួតពិនិត្យសាច់ និងផលិតផលសត្វ

- កន្លែងព្យួរផ្ទាំងសាច់ និងផលិតផលសត្វ សម្រាប់មន្ត្រីបសុពេទ្យមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ និង បោះត្រា មុនធ្វើការនាំចេញពីសត្តឃាតដ្ឋាន
- កន្លែងពន្លះសាច់ ឬ កាត់សាច់ជាដុំៗ

ជ. កន្លែងសម្រាប់រក្សាទុកសាច់ និង ផលិតផលសត្វ : បន្ទប់ត្រជាក់សម្រាប់ថែរក្សាសាច់ និងផលិតផលសត្វ និង បន្ទប់ត្រជាក់សម្រាប់ថែរក្សាសាច់ និង ផលិតផលសត្វ ដែលសង្ស័យថាមានមេរោគ ដើម្បីរង់ចាំលទ្ធផលពីមន្ទីរពិសោធន៍។

ឈ. កន្លែងកំទេចសត្វ សាច់ និង ផលិតផលសត្វដែលមានមេរោគ : កន្លែងសម្រាប់ពិឃាតសត្វឈឺ និង ឡសម្រាប់ដុតកំទេចចោលសត្វ សាច់ និង ផលិតផលសត្វ។

ញ. កន្លែងសម្រាប់ទុកដាក់ផលិតផលសត្វ មិនអាចបរិភោគបានជាអាទិ៍ ឆ្អឹង រោម ស្បែក ស្នែង ក្រចក និងលាមក។

**ប្រការ ៤ :** អគារពិឃាតសត្វ ត្រូវកំណត់ដូចខាងក្រោម ÷

ក.ត្រូវមានច្រកពីរដាច់ដោយឡែកពីគ្នា សម្រាប់បញ្ចូលសត្វរស់ និង សម្រាប់បញ្ចេញសាច់ និង ផលិតផលសត្វ

ខ. ដំណើរការពិឃាតសត្វ ត្រូវរៀបចំ និង កំណត់ដូចខាងក្រោម ÷

-ត្រូវអនុវត្តតាមគំនូសប្លង់មេ នៃដំណើរការពិឃាតសត្វដែលមានឧបសម្ព័ន្ធភ្ជាប់ក្នុងប្រកាសនេះ

- ដំណើរការពិឃាតសត្វ ត្រូវមានខ្សែរសង្វាក់តាមលំដាប់លំដោយ ចាប់តាំងពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលចុងក្រោយ។

គ. អាគារពិឃាតសត្វ:

- ត្រូវរៀបចំអគារឱ្យបានត្រឹមត្រូវ តាមលក្ខណៈបច្ចេកទេស ដើម្បីធានាសុខភាពសាធារណៈ និង បរិស្ថាន
- ជញ្ជាំងត្រូវមានភាពរឹងមាំ ធន់សំណើម ធន់ការប៉ះទង្គិច មិនពុកផុយ ផ្ទៃរាបស្មើរលោង
- មុំនៃជ្រុងជញ្ជាំងត្រូវមានរាងកោង ងាយស្រួលដុសលាងសម្អាត និង សម្លាប់មេរោគ
- ផ្ទៃក្រាលត្រូវមានភាពរឹងមាំ មិនរអិល មិនជ្រាបនិងសារធាតុរាវ ធន់និងអាស៊ីត មានជម្រាល ភ្ជាប់ទៅ

បណ្ដាញលូ ងាយស្រួលលាងសម្អាត និង សម្លាប់មេរោគ

- ត្រូវមានពិតានរាបស្មើ ធន់សំណើម និង លាបថ្នាំពណ៌ភ្លឺរលោង
- ត្រូវបំពាក់ប្រព័ន្ធអគ្គិសនីឱ្យបានគ្រប់គ្រាន់ ទៅតាមលក្ខណៈបច្ចេកទេស
- ត្រូវបំពាក់ប្រព័ន្ធទឹកស្អាត ក្ដៅ និង ត្រជាក់ ឱ្យបានគ្រប់គ្រាន់
- ត្រូវបំពាក់ឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងដំណើរការពិឃាត ធ្វើអំពីលោហៈធាតុ ធន់និងអុកស៊ីតកម្ម សមស្របតាមលក្ខណៈបច្ចេកទេស ងាយស្រួលលាងសម្អាត និង សម្លាប់មេរោគ
- ត្រូវរៀបចំប្រព័ន្ធបង្ហូរកាកសំណល់ ឱ្យសមស្របតាមលក្ខណៈបច្ចេកទេសធានាមិនឱ្យមានក្លិន និង ការពារសត្វចង្រៃមិនឱ្យចេញចូលបាន
- កន្លែងពន្លះសាច់ ឬ កាត់បំបែកសាច់ជាដុំៗ ត្រូវរៀបចំឱ្យផុតពីផ្ទៃក្រាល មានកំពស់យ៉ាងតិច ៨០ (ប៉ែតសិប) សង់ទីម៉ែត្រ។ ផ្ទៃខាងលើដែលប៉ះផ្ទាល់និងសាច់ ឬ ផលិតផលសត្វ ត្រូវមានភាពរលោង ពុំមានប្រហោង ស្នាមរបើក ឬ ស្នាមប្រេះ ធន់និងសកម្មភាពនៃការកាប់បំបែកសាច់។

**ប្រការ ៥ :** សំណល់ឥតប្រយោជន៍គ្រប់ប្រភេទ ត្រូវតែបញ្ចេញចោលពីកន្លែងធ្វើការជាប្រចាំ ដោយត្រូវស្តុកទុកក្នុងអាងដែលមានគម្របអាចបិទបើកបាន និងប្រមូលចោលជាអចិន្ត្រៃយ៍ដើម្បីការពារកុំឱ្យមានក្លិន សត្វចង្រៃផ្សេងៗចេញចូលបាន ជៀសវាងមានការចម្លងមេរោគដល់សាច់ ផលិតផលសត្វ ទឹកស្អាត និង ឧបករណ៍ប្រើប្រាស់ផ្សេងៗទៀត។

បណ្ដាញបំពង់បង្ហូរកាកសំណល់ និង បណ្ដាញបញ្ចេញសំណល់រាវ រួមទាំងបណ្ដាញលូទឹកកខ្វក់ ត្រូវមានចំនួនគ្រប់គ្រាន់ ដើម្បីធានាការបញ្ចេញទឹកកាកសំណល់ ។ ទឹកកខ្វក់ទាំងឡាយ ត្រូវតែបញ្ចូលទៅក្នុងអាងប្រព្រឹត្តិកម្ម ឬ ឡជីវឧស្ម័ន មុននិងបញ្ចេញចោល។

**ប្រការ ៦:** ប្រកាស ឬ សេចក្ដីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជា និរាករណ៍។

**ប្រការ ៧ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល គ្រប់ប្រធានអង្គភាពដែលមានការពាក់ព័ន្ធ ប្រធានមន្ទីរកសិកម្ម និង ប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាល ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារៈកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី.............ខែ................ឆ្នាំ ២០០៨

**រដ្ឋមន្ត្រី**

**<u>កន្លែងទទួល</u>** :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួង ស្ថាប័នពាក់ព័ន្ធ

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី

តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

-គ្រប់សាលាខេត្ត ក្រុង

-ដូចប្រការ ៧

-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ១៨

## ប្រកាសស្តីពីបទបញ្ជាផ្ទៃក្នុងរបស់សត្តឃាតដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ.........................................កសក

**ប្រកាស**

**ស្តីពី**

**បទបញ្ជាផ្ទៃក្នុង របស់សត្តឃាតដ្ឋាន**

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និង

ស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និង ឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**ប្រការ ១ :** ដាក់ឱ្យប្រើប្រាស់បទបញ្ជាផ្ទៃក្នុង របស់សត្តឃាតដ្ឋាន ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល គ្រប់ប្រធានអង្គភាពដែលមានការពាក់ព័ន្ធ ប្រធានមន្ទីរកសិកម្ម និង ប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាល ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារៈកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី.............ខែ.................ឆ្នាំ ២០០៨

**រដ្ឋមន្ត្រី**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-គ្រប់សាលាខេត្ត ក្រុង
-ដូចប្រការ ៣
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ភ្ជាប់ប្រកាសលេខ..............ប្រក.កសក
ចុះថ្ងៃទី..........ខែ.............ឆ្នាំ ២០០៨

# បទបញ្ជាផ្ទៃក្នុងរបស់សត្តឃាតដ្ឋាន

ដើម្បីធានាបាននូវអនាម័យសត្វ សាច់ និង ផលិតផលសត្វ សំដៅរក្សាបានសុវត្ថិភាពចំណីអាហារ និង សុខភាពសាធារណៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សម្រេចកំណត់នូវបទបញ្ជាផ្ទៃក្នុង សម្រាប់សត្តឃាតដ្ឋានទាំងអស់ដូចខាងក្រោម ៖

## ១. អនាម័យសត្តឃាតដ្ឋាន អនាម័យសម្ភារៈពិឃាតសត្វ និង សណ្តាប់ធ្នាប់ក្នុងសត្តឃាតដ្ឋាន

- សត្តឃាតដ្ឋានត្រូវមានអនាម័យ និង ធ្វើការលាងសម្អាត សម្លាប់មេរោគតាមលក្ខណៈបច្ចេកទេសបសុពេទ្យ
- សម្ភារៈប្រើប្រាស់សម្រាប់ការពិឃាតសត្វ ត្រូវមានអនាម័យល្អ
- អ្នកគ្មានភារៈកិច្ច ហាមចេញ ចូល សត្តឃាតដ្ឋានដោយគ្មានការអនុញ្ញាត
- ត្រូវរក្សាសណ្តាប់ធ្នាប់ សន្តិសុខ និង របៀបរៀបរយក្នុងសត្តឃាតដ្ឋាន។

## ២. អនាម័យ និង សុខុមាលភាពសត្វ មុនពិឃាត

- សត្វសម្រាប់ពិឃាត ត្រូវរក្សាទុកនៅកន្លែងបង្ខាំងសត្វក្នុងសត្តឃាតដ្ឋាន រយៈពេលពី ១២-២៤ ម៉ោង (ដប់ពីរទៅម្ភៃបួន) មុនធ្វើការពិឃាត ដើម្បីឱ្យភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ចត្រួតពិនិត្យសុខភាព
- សត្វត្រូវផ្តល់ទឹកផឹកឱ្យបានគ្រប់គ្រាន់ តែមិនផ្តល់អាហារឡើយ ក្នុងរយៈពេលបង្ខាំងនេះ
- ហាមធ្វើទារុណកម្មសត្វដូចជា: វាយដំ បញ្ជ្រុកទឹក បញ្ជ្រុកចំណី និង ការធ្វើទារុណកម្មតាមរូបភាពផ្សេងៗទៀត
- សត្វអាចពិឃាតបាន លុះត្រាតែមានការអនុញ្ញាតពីភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច នៅក្នុងសត្តឃាតដ្ឋាននោះ
- សត្វត្រូវលាងសម្អាតឱ្យបានស្អាត មុនធ្វើការពិឃាត។

## ៣. អនាម័យផ្ទាំងសាច់ និង ផលិតផលសត្វ

- ផ្ទាំងសាច់ និង ផលិតផលសត្វ ត្រូវលាងសម្អាត រក្សាទុក ឬ ព្យួរតាមលក្ខណៈបច្ចេកទេស
- សាច់ និង ផលិតផលសត្វ ត្រូវតែឆ្លងកាត់ការត្រួតពិនិត្យអនាម័យ បោះត្រា ឬ អូសត្រា ឬ បិទស្លាកសម្គាល់លើកញ្ចប់សាច់ និង មានវិញ្ញាបនបត្របញ្ជាក់អនាម័យ ពីភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច មុនធ្វើការនាំចេញពីសត្តឃាតដ្ឋាន
- អាជីវករពិឃាតសត្វ ត្រូវតែបង្កលក្ខណៈងាយស្រួល ដល់ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច ក្នុងការត្រួតពិនិត្យសត្វ សាច់ ផលិតផលសត្វ និង ការយកវត្ថុវិភាគ។

## ៤. អនាម័យបុគ្គលិក កម្មករ និង អ្នកបំពេញការងារក្នុងសត្តឃាតដ្ឋាន

- បុគ្គលិក កម្មករ និង អ្នកបំពេញការងារក្នុងសត្តឃាតដ្ឋាន ត្រូវមានសុខភាពល្អ (មានលិខិតបញ្ជាក់សុខភាពពីមន្ទីរសុខាភិបាល /អង្គភាពមានសមត្ថកិច្ច)
- ត្រូវមានអនាម័យល្អ ហាមខាកស្ដោះ និង ជក់បារី ក្នុងពេលម៉ោងកំពុងធ្វើការ ។

## ៥. សម្លៀកបំពាក់ សម្រាប់អ្នកបំពេញការងារនៅក្នុងសត្តឃាតដ្ឋាន

- អាវដៃខ្លី ឬ ដៃវែងជីបចុងដៃ ក្រណាត់ពណ៌ផ្ទៃមេឃ
- ខោជើងវែង ក្រណាត់ពណ៌ផ្ទៃមេឃ
- គម្របក្បាល ក្រណាត់ពណ៌ផ្ទៃមេឃ
- ស្បែកជើងកវែង មិនជ្រាបទឹក ពណ៌ស
- អាវអៀមផ្លាស្ទិក ពណ៌ស
- ស្រោមដៃ ពណ៌ស ។

# ឧបសម្ព័ន្ធ ១H

## បញ្ជីរាយឈ្មោះជំងឺសំខាន់ៗ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វ

| | |
|---|---|
| **១- ជំងឺឆ្លង** | |
| - ជំងឺឈាមខ្មៅ | Anthrax |
| - ជំងឺអុតក្តាម | Foot and Mouth Disease |
| - ជំងឺសាទឹក | Pasteurellosis/Haemorrhagic Septicemia |
| - ជំងឺប្រ៊ុយសែលឡូស | Brucellosis |
| - ជំងឺតេតាណូស | Tetanus |
| - ជំងឺរបេង | Tuberculosis |
| - ជំងឺគោឆ្កួត | Bovine Spongiform Encephalopathy |
| - ជំងឺបូសខ្យល់ | Black leg |
| - ជំងឺកាំពីឡូបាក់តេរីយ៉ូស | Campilobacter enteritis |
| - ជំងឺប៉េស្ត | Classical Swine Fever/Hog Cholera |
| - ជំងឺកញ្ជ្រិល | Erysipelas |
| - ជំងឺស្រ្តិបតូកុក | Streptococcus infection |
| - ជំងឺសាលម៉ូណែឡា | Salmonellosis |
| **២- ជំងឺបង្កដោយប៉ារ៉ាស៊ីត** | |
| - ជំងឺចុងអង្ករគោ ក្របី | Bovine cysticercosis |
| - ជំងឺចុងអង្ករជ្រូក | Porcine cysticercosis |
| - ជំងឺទ្រីគីន | Trichinellosis |
| - ជំងឺហ្វាស្យូឡា | Fasciolosis |

| | |
|---|---|
| - ជំងឺចុងអង្ករគោ ក្របី | Bovine cysticercosis |
| - ជំងឺចុងអង្ករជ្រូក | Porcine cysticercosis |
| - ជំងឺទ្រីគីន | Trichinellosis |
| - ជំងឺហ្វាស្យូឡា | Fasciolosis |

# ឧបសម្ព័ន្ធ ២A

## សហគ្រាសសិប្បកម្មតម្រូវសុំប្រកាសអនុញ្ញាត

| | |
|---|---|
| កែច្នៃអាហារ | (លើសពី ២៥០ តោន ក្នុង ១ឆ្នាំ) |
| ទឹកកក និងទឹកបរិសុទ្ធ | (លើសពី ១ តោន ក្នុង ១ឆ្នាំ) |
| ទឹកក្រូច ទឹកស៊ីរ៉ូ សូដា | (គ្រប់ទំហំ) |
| ផលិត និងកែច្នៃស្រា | (គ្រប់ទំហំ) |
| កែច្នៃស្រាបៀរ និងស្រា | (គ្រប់ទំហំ) |
| ទឹកស៊ីអ៊ីវ ទឹកស្ប៉ៀវ ទឹកម្ទេស ទឹកប៉េងប៉ោះ | (គ្រប់ទំហំ) |
| ទឹកត្រី | (លើសពី ៥០០,០០០ លីត្រ ក្នុង ១ ឆ្នាំ) |
| ប្រព្រឹត្តិកម្មសំអាតទឹកផ្គត់ផ្គង់ និងចែកចាយ | (គ្រប់ទំហំ) |
| ប្រេងឆា | (គ្រប់ទំហំ) |
| នំប៉័ង និងនំផ្អែម | (គ្រប់ទំហំ) |

# ឧបសម្ព័ន្ធ ២B

## ពាក្យស្នើសុំវិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រើសញ្ញាបញ្ជាក់ផលិតផល

Institute of Standards of Cambodia (ISC)

ឧបសម្ព័ន្ធ ១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

### ពាក្យស្នើសុំវិញ្ញាបនបត្រ និងអាជ្ញាប័ណ្ណប្រើសញ្ញាបញ្ជាក់ផលិតផល

